ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អត្ថបទស្រាវជ្រាវ

# ដើមកំណើតជាតិខ្មែរ

សាស្ត្រាចារ្យបង្រៀនៈ លោក អ៊ុក វិបុល
រៀបរៀងដោយៈ និស្សិតក្រុមទី១៦ (ស.ភ.ន.វ.ស/RULE)

# អារម្ភកថា

កម្រងឯកសារដែលទ្រង់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោក-លោកស្រី សាស្ត្រាចារ្យ និស្សិត និង អ្នកសិក្សាស្រាវជ្រាវកំពុងតែអាននេះមានចំណងជើងថា "**ដើមកំណើតជាតិខ្មែរ**" ដែលជាសមិទ្ធផលនៃការខិតខំប្រឹងប្រែងស្រាវជ្រាវ និង រៀបចំដោយយើងខ្ញុំជាក្រុមនិស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ក្រុម$L_1B_6$ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

កម្រងឯកសារមួយនេះ ត្រូវបានប្រសូតឡើងដោយការសិក្សាស្រាវជ្រាវពីឯកសារនានា និងតាមទស្សនៈអ្នកប្រាជ្ញ និងកវីក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាក្នុងពិភពលោកដែលបានធ្វើការសិក្សាពីដើមកំណើតនៃជាតិខ្មែរ យកមកចងក្រងបញ្ចូលគ្នាក្នុងគោលបំណងផ្តល់ភាពងាយស្រួលដល់ការសិក្សាស្រាវជ្រាវ និងបង្កើនចំណេះដឹងដល់ក្រុមនិស្សិតឲ្យយល់ពីជាតិរបស់ខ្លួនឲ្យកាន់តែច្បាស់ផងដែរ។

យើងខ្ញុំមានសេចក្តីសោមនស្សរីករាយឥតគណនា ដែលមានឱកាសចងក្រងឯកសារនេះឡើង។ ទាំងអស់នេះគឺដើម្បីជួយជំរុញឲ្យប្រជាពលរដ្ឋខ្មែរមានចំណេះដឹង និងស្គាល់ពីជាតិរបស់ខ្លួនកាន់តែច្បាស់ ព្រមទាំងបណ្តុះស្មារតីចេះស្នេហា និងថែរក្សាជាតិខ្មែរឲ្យគង់វង្សរហូតតទៅ។ យើងខ្ញុំសង្ឃឹមជឿជាក់ថា ឯកសារនេះនឹងផ្តល់នូវពុទ្ធិ និងជះឥទ្ធិពលដល់និស្សិត និង ពលរដ្ឋគ្រប់រូបឲ្យគោរពស្រលាញ់ជាតិខ្មែរយ៉ាងពិតប្រាកដ ព្រមទាំងជៀសវាងនូវការយល់ច្រឡំផ្សេងៗនៃកំណើតជាតិខ្មែរ។

ជាចុងបញ្ចប់យើងខ្ញុំសូមប្រសិទ្ធិពរជ័យដល់ក្រុមនិស្សិត ក៏ដូចជាប្រជាពលរដ្ឋទូទៅឲ្យជួបប្រទះនឹងសំណាងល្អ សុខភាពល្អ ចិត្តគំនិតជ្រះថ្លា និង ការសិក្សាស្រាវជ្រាវប្រកបដោយជោគជ័យ គ្រប់ពេលវេលា និង គ្រប់ទីកន្លែង។

សូមជនរួមជាតិខ្មែរគ្រប់រូបចងចាំថា តម្លៃពិតប្រាកដរបស់ជាតិ គឺស្ថិតនៅត្រង់ការខិតខំប្រឹងប្រែង យកចិត្តទុកដាក់ក្នុងការសិក្សា ស្វែងយល់ពីជាតិសាសន៍ របស់យុវនិស្សិតបច្ចុប្បន្ន រួមទាំងកូនខ្មែរជំនាន់ក្រោយៗទៀត។

ធ្វើនៅភ្នំពេញ, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១

ថ្នាក់ $L_1B_6$ ផ្នែកនីតិសាស្ត្រ

ក្រុមទី ១៦

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតឆ្នាំសិក្សាមូលដ្ឋាន ក្រុម$L_1B_6$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណ និងសម្តែងនូវការគោរពយ៉ាងស្មោះស្ម័គ្រចំពោះ ៖

- មាតាបិតាយើងខ្ញុំ ដែលបានផ្តល់កំណើត ជួយផ្គត់ផ្គង់ ជ្រោមជ្រែង ឧបត្ថម្ភទាំងសម្ភារៈ និងថវិកាគ្រប់បែបយ៉ាង ព្រមទាំងជំរុញលើកទឹកចិត្ត ឲ្យយើងខ្ញុំបានសិក្សាក្រេបយកចំណេះដឹង និងក្លាយជាពលរដ្ឋល្អក្នុងសង្គមដូចថ្ងៃនេះ។
- ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈកម្មការ និងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំដឹកនាំ និងគ្រប់គ្រងក្នុងគោលបំណងបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីជាសរសរទ្រូងនៃប្រទេសជាតិ។
- លោកសាស្ត្រាចារ្យ **អ៊ុក ខេមុណ** ដែលជាសាស្ត្រាចារ្យមុខវិជ្ជាវប្បធម៌ទូទៅនៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដែលបានបង្ហាត់បង្រៀន ជួយលើកទឹកចិត្ត ត្រួសត្រាយផ្លូវ និងផ្តល់ដំបូន្មានល្អៗដល់កិច្ចការស្រាវជ្រាវនេះ។

# មាតិកា

ទំព័រ


- **អារម្ភកថា** ........ i
- **សេចក្តីថ្លែងអំណរគុណ** ........ ii
- **មាតិកា** ........ iii

I. សេចក្តីផ្តើម ........ ១

II. តួសេចក្តី ........ ៣

ក. តាមទស្សនៈរបស់អ្នកស្រាវជ្រាវ ........ ៣

១. ជនជាតិខ្មែរមានដើមកំណើតពីឥណ្ឌា ........ ៣

២. ជនជាតិខ្មែរមានដើមកំណើតជាជាតិពិសេសមួយ ........ ៤

ខ. ភស្តុតាងដែលបញ្ជាក់ថាខ្មែរជាជាតិពិសេសមួយ ........ ៦

១. សាសនា (ជំនឿ) ........ ៦

២. ទំនៀមទំលាប់ ........ ៨

៣. ភាសា និងអក្សរ ........ ១០

៣.១. ភាសា ........ ១០

៣.១.១. ការវិវត្តភាសា ........ ១១

៣.១.២. អំបូរភាសា ........ ១១

៣.១.៣. ប្រវត្តិនៃភាសា ........ ១២

៣.១.៤. វិវត្តន៍នៃភាសាខ្មែរ ........ ១៤

៣.១.៥. ការសម្គាល់ពាក្យកម្ចីបាលី សំស្រ្កឹតនៅក្នុងភាសាខ្មែរ ........ ១៥

៣.១.៦. លក្ខណៈពិសេសនៃភាសាខ្មែរ ........ ១៦

៣.២. អក្សរ ........ ២២

៣.២.១. ប្រវត្តិនៃអក្សរ ........ ២២

៣.២.២. វិវត្តន៍នៃអក្សរខ្មែរ ........ ២៤

៣.២.៣. លក្ខណៈពិសេសនៃអក្សរខ្មែរ ........ ២៥
៤. ស្ថានីយ៍បុរេប្រវត្តិ ........ ២៨
៤.១. ស្ថានីយ៍ព្រៃកឆ្លូង ........ ២៨
៤.២. ស្ថានីយល្អាងស្ពាន ........ ២៨
៤.៣. ស្ថានីយភ្នំក្បាលរមាស ........ ២៩
៤.៤. ស្ថានីយ៍សំរោងសែន-អន្លង់ផ្ដៅ-ម្លូព្រៃ ........ ២៩
៥. កត្តាជីវសាស្រ្ត ........ ៣១
៦. ប្រភពរឿងព្រេង ........ ៣២
III. សេចក្ដីបញ្ចប់ ........ ៣៤

# ដើមកំណើតជាតិខ្មែរ

## I. សេចក្តីផ្តើម

គ្រប់ប្រទេសនៅលើសាកលលោក តែងតែកើតចេញពីក្រុមមនុស្សដែលជាអ្នកបង្កើតជាតិសាសន៍រៀងៗខ្លួន។ ជាតិសាសន៍របស់មនុស្ស គឺបានមកពីមនុស្សជាអ្នកបង្កើត និងកែច្នៃ។ ពួកគេទាំងនោះបានបង្កើតទឹកដី អរិយធម៌ វប្បធម៌ ទំនៀមទំលាប់ ប្រពៃណី ភាសា អក្សរ និងរបៀបរស់នៅក្នុងសង្គមរបស់ពួកគេ។ ជាតិសាសន៍ខ្លះពុំមានអរិយធម៌របស់ខ្លួនទេ គឺលួចចម្លងពីជាតិសាសន៍ដទៃ ឬយកមកកែច្នៃឲ្យក្លាយជារបស់ខ្លួន។ ដោយឡែកជាតិសាសន៍ខ្លះក៏មានអរិយធម៌របស់គេផ្ទាល់ដែរ។ ជនជាតិខ្មែរត្រូវបានចាត់ទុកថាជាជនជាតិមួយដែលមានអរិយធម៌ចំណាស់ជាងគេ។ យ៉ាងណាមិញ ជនជាតិខ្មែរបានឆ្លងកាត់នូវទិដ្ឋភាពជាច្រើនតាមសម័យកាលនីមួយៗ មានទាំងភាពរុងរឿង និងជូរចត់។ មិនតែប៉ុណ្ណោះ ប្រទេសខ្មែរបានជួបប្រទះនូវភាពរីកររនៅក្នុងផ្ទៃប្រទេសដោយសារតែភាពធ្វេសប្រហែសរបស់អ្នកដឹកនាំខ្មែរមួយចំនួន និងការឈ្លានពានយ៉ាងឃោរឃៅរបស់ប្រទេសជិតខាង។ ដោយហេតុនេះហើយ ទើបធ្វើឲ្យខ្មែរទទួលរងគ្រោះដោយបាត់បង់នូវភស្តុតាងជាច្រើនដែលបញ្ជាក់ពីអត្តសញ្ញាណ និងដើមកំណើតរបស់ខ្លួន។ បញ្ហានេះតែងតែចោទឡើង នៅពេលដែលគេធ្វើការសិក្សាស្រាវជ្រាវពីអរិយធម៌ និងប្រវត្តិសាស្ត្រខ្មែរ។ កូនខ្មែរគ្រប់ៗរូបគួតែយល់ដឹងឲ្យបានច្បាស់ពីបញ្ហានេះ។ ដើម្បីដោះស្រាយនូវបញ្ហា និងដើម្បីបញ្ចៀសនូវរាល់ការភាន់ច្រលំ ទោះបីជាមានឧបសគ្គយ៉ាងណាក៏ដោយ ក៏មានអ្នកសិក្សាស្រាវជ្រាវមួយចំនួនបានព្យាយាមបើកកកាយនូវទំព័រប្រវត្តិសាស្ត្រ ដោយធ្វើការស្រាវជ្រាវតាមរយៈភស្តុតាងខ្លះដែលបន្សល់តាំងពីបុរាណកាលមក។ ក្នុងនោះ អ្នកសិក្សាស្រាវជ្រាវបានសិក្សាទៅលើស្ថានីយ៍ប្រវត្តិសាស្ត្រ ជីកកកាយ និងពិសោធវត្ថុប្រើប្រាស់ផ្សេងៗពីបុរាណ ព្រមទាំងបានសិក្សាបន្ថែមទៅលើសាសនា ទំនៀមទំលាប់ប្រពៃណី អក្សរ ភាសា កត្តាជីវសាស្ត្រ និងប្រភពរឿងព្រេងផ្សេងៗទៀត។ ដោយសារតែភស្តុតាងទាំងនេះហើយទើបធ្វើឲ្យអ្នកសិក្សាស្រាវជ្រាវអាចធ្វើការសន្និដ្ឋានពីដើមកំណើតជាតិខ្មែរនេះបាន។

ទោះបីជាបានឆ្លងកាត់ការសិក្សាស្រាវជ្រាវយ៉ាងល្អិតល្អន់យ៉ាងណាក៏ដោយ ក៏វានៅតែមានចំណោទបញ្ហាដែលកើតចេញពីការយល់ឃើញរបស់អ្នកសិក្សាស្រាវជ្រាវ ដោយពួកគេធ្វើការបញ្ចេញទស្សនៈខុសៗគ្នាដោយសម្អាងលើភស្តុតាងរៀងៗខ្លួន។ ដូចនេះ បញ្ហានេះនៅតែជាចម្ងល់របស់កូនខ្មែរ។ ប៉ុន្តែយើងក៏អាចធ្វើការប្រមូលផ្តុំនូវសមិទ្ធកម្មនៃបញ្ហាដើមកំណើតជាតិខ្មែរនេះដែរ គឺមតិដែលថាខ្មែរមានដើមកំណើតមកពីឥណ្ឌា និងមតិដែលថាខ្មែរមានដើមកំណើតជាជាតិពិសេសមួយ។ ដោយសារតែមានមតិទាំងនេះហើយ ទើបកើតមានការចោទសួរថា "តើខ្មែរមានដើមកំណើតពីណាពិតប្រាកដ ហើយដោយសម្អាងលើភស្តុតាងអ្វីខ្លះ?" ។

# II. តួសេចក្ដី

## ក. តាមទស្សនៈរបស់អ្នកស្រាវជ្រាវ

អ្នកសិក្សាស្រាវជ្រាវពីខ្មែរជាច្រើន បានព្យាយាមសិក្សាស្រាវជ្រាវស្វែងរកពីដើមកំណើតពិតប្រាកដរបស់ខ្មែរ។ មតិដែលគេប្រមូលបាននោះមានពីរខុសៗគ្នាគឺ ខ្មែរមានដើមកំណើតមកពីឥណ្ឌា និងខ្មែរមានដើមកំណើតជាជាតិពិសេសមួយ។

### ១. ខ្មែរមានដើមកំណើតមកពីឥណ្ឌា

ទស្សនៈបែបនេះ លោកឧកញ៉ា**ឈឹម ក្រសេម** បានបញ្ជាក់យ៉ាងពឹស្ដារក្នុងសៀវភៅ "**ពង្សាវតារខ្មែរភាគ១**" បោះពុម្ពនៅភ្នំពេញគ.ស**១៩៧១**។ លោកបានសរសេរជាអាទិ៍ថា ៖ តាមដែលបានស្រាវជ្រាវតាមផ្លូវប្រវត្តិសាស្ត្រមកហើយ ប្រាកដថា ដែនឥណ្ឌាភាគខាងត្បូងក្នុងចំណោមប្រទេសឯទៀត គឺត្រង់ដែលហៅថា**ទក្ខិណាបថ** ឬ **ទក្សិណាទ្វីគោល**មានប្រទេសមួយឈ្មោះ"**កុមេរុ**" ដែលជាប្រទេសធំមានប្រជាជនកុះករច្រើនគឺជាប្រទេសរបស់ខ្មែរអំពីបុរាណកាលមក ។...ឈ្មោះជាតិខ្មែរហៅត្រឹមត្រូវតាមសូរស័ព្ទ ដើមថា"**កុមេរុ**" ដូច្នេះតែតាមសំលេងនិយាយជាធម្មតាថា**កុមេរ៍**ទំនងដូចឈ្មោះ**ភ្នំសុមេរ៍**។ លុះយូរមកឈ្មោះនេះបានក្លាយចេញទៅទៀតប្រាកដនៅសិលាចារឹករបស់ខ្មែរថា "**ក្មេរ**" ទៅជាសម្លេងផ្សំ ក្រោយសម័យសិលាចារឹកមកបានប្រែថា "**ខ្មែរ**"។...តាំងពីក្រោយពុទ្ធកាលប្រមាណ២០០ឆ្នាំជាដើមមក ជនជាតិខ្មែរបានផ្ដើមផ្សាយមកក្នុងដែន**សុវណ្ណភូមិ**។...ពួកខ្លះមកដោយប៉ងដើម្បីរកស៊ីលក់ដូរតាមធម្មតា ពួកខ្លះមកដោយរត់សឹក។ ...អ្នកដែលនាំអារ្យធម៌ពីឥណ្ឌាមកផ្សាយក្នុងដែនដីអាយនេះគឺ ខ្មែរអាស្រ័យជាតិខ្មែរជាអ្នកមានអារ្យធម៌ខ្ពង់ខ្ពស់ ទាំងមានឥទ្ធិពលទើបអាចផ្សាយអារ្យធម៌របស់ខ្លួនទៅលើជាតិទាំងឡាយដែលនៅក្រោមអំណាច និងជាតិទាំងឡាយដែលនៅជិតខាងទៀតផង ដោយហេតុនេះទើបមានឆាយាថាៈ"**ខ្មែរជាឥណ្ឌាទី២នៅក្នុងដែនសុវណ្ណភូមិ**"។ ខដែលថា "ខ្មែរយើងផ្សាយមកពីឥណ្ឌា" ដូច្នេះតើមានអ្វីខ្លះជាសំអាងតបថាក្រៅពីជាតិ និងឈ្មោះប្រទេសដូចពោលហើយនៅមានភស្តុតាងយ៉ាងដទៃទៀតជាច្រើនយ៉ាងជាសំអាងៈ

- លក្ខណៈអក្សរនិងភាសា
- លទ្ធិប្រពៃណីនិងសាសនា

~ពង្សាវតារនិងសេចក្ដីកត់ហេតុ

...ជាតិខ្មែរ និងជាតិថ្វាជាម្ចាស់ស្រុកដើម បានរួមគ្នាទៅជាជាតិមួយហៅថា**កុមេរុ**គឺជាខ្មែរសព្វថ្ងៃនេះ។...ខ្មែរក្នុងជំនាន់ដើមរូបរាងច្រើនស្រងៗច្រមុះស្រួច សម្បុរកាយខ្មៅស្រអែម..ឯជនជាតិថ្វាលក្ខណ:រូបរាងជាយ៉ាងមធ្យមសម្បុរកាយសជ្រះរូបច្រើនល្អ។...ពង្សាវតារភូមាថា**មន** និង**ខ្មែរ**ជាបងប្អូនផងគ្នាចុះមកអំពីឥណ្ឌាទាំងពីរពួក តែពួកមនផ្សាយមកមុនគេបន្តិច ។

ទស្សនៈរបស់លោកឧកញ៉ា**ឈឹម ក្រសេម** ខាងលើនេះមានជនបរទេសយល់ស្របតាម និងយកទៅប្រើប្រាស់ជាផលប្រយោជន៍របស់គេថែមទៀត ។ លោក*Pierre Loti* អ្នកនិពន្ធបារាំងដ៏ល្បីល្បាញមួយរូបបានសរសេរក្នុងសៀវភៅឈ្មោះ **Pèlerin d'Angkor** ថា « le people khmer, Rameau détaché de la grande race aryenne... »(ប្រជារាស្ត្រខ្មែរជាមែកធាងដែលដាច់ចេញពីមហាអំបូរអារ្យ...) ។ ចំនែកលោកមុំសេនីប្រាមោជមេធាវីថៃអមតុលាការអន្តរជាតិនាទី**ក្រុងឡាអេ (La Haye)** បានលើកយកទស្សនៈបែបនេះមកធ្វើជាទមិឡដើម្បីប្រឆាំងនឹងខ្មែរយើងក្នុងរឿងក្ដីប្រាសាទព្រះវិហារហើយដែលសារពត៌មានសៀមឈ្មោះ"**ឆាវ ថៃ**" ចុះថ្ងៃទី៣១តុលា១៩៥៩បានរំលឹកថា: "មុំសេនីប្រាមោជ បាននិយាយថាពពួក"**ខម**"ជាជនពូជអំបូរឥណ្ឌា។ ជនជាតិថៃមានដើមកំណើតក្នុងខេត្តចិនយូនណាន បានវាយយកជោគជ័យទៅលើជាតិ**ខម**រហូតដល់ពួកនេត្រលប់ទៅស្រុកឥណ្ឌាវិញ។ ដែនដីដែលពីដើមពួក**ខម**តាំងនៅក៏ក្លាយទៅជាដីថៃហើយប្រជាជនថៃក៏ចែកខ្លួនឯងជាពីរក្រុម។ ក្រុមទីមួយមកតាំងនៅតំបន់ទំនាបដែលគេឲ្យឈ្មោះសព្វថ្ងៃ"**កម្ពុជា**" ឯក្រុមមួយទៀត បានតាំងនៅតំបន់ខ្ពស់ហើយនៅថៃរក្សាឈ្មោះ**ថៃ**ដដែល ។

## ២. ខ្មែរមានដើមកំណើតជាជាតពិសេសមួយ

យោបល់ដែលទទួលស្គាល់ថា ជាតិខ្មែរជាជាតិពិសេសមួយស្ថិតក្នុងអំបូរមន-ខ្មែរហើយបានកកើតឡើង នៅភូមិភាគអាស៊ីអាគ្នេយ៍នេះតែម្តង។ នេះគឺជាទស្សនៈរបស់លោក **Bernard Philipe Groslier** និង **Marcel Talabot** ជាដើម។ លោកទាំងពីរនេះយល់ថាក្នុងសម័យ បុព្វប្រវត្តិសាស្ត្រដ៏យូរលង់ណាស់មកហើយ មានមនុស្សពូជខុសៗគ្នាបានធ្វើដំណើរពីខាងជើងចុះមកអាស៊ីអាគ្នេយ៍ ហើយផ្សំកាត់ជាមួយគ្នា។ តាមការប៉ាន់ស្មានរបស់លោកទាំងពីរ អំបូរខ្មែរ-មនយើងកើតពីរការផ្សំកាត់រវាងពូជមេឡានេស៊ីយាង និងពូជឥណ្ឌូនេស៊ីយាង ហើយបានរស់នៅលើទឹកដីលាតសន្ធឹងពីឆ្នេរសមុទ្រចិន រហូតដល់ព្រំប្រទល់ប្រទេសឥណ្ឌា។

គួរកត់សម្គាល់ផងដែរថា យោបល់ទីបីនេះមានលក្ខណៈស្របទៅនឹងទស្សនៈរបស់ខ្មែរ ពីព្រោះបើយើងសំអាងទៅលើរឿងព្រេងខ្មែរក៏ដោយ លុះត្រាតែមាននាងនាគនៅស្រុកខ្មែរនេះឯង ទើបព្រះថោង (ដែលគេថាមកពីប្រទេសឥណ្ឌា) បានជួបប្រភពគ្នាដោយបានគ្រប់គ្រងស្រុកគកធ្លកនេះដែរ ទើបឥណ្ឌាអាចផ្សាយអរិយធម៌របស់ខ្លួនបានខ្លះ ចូលក្នុងស្រុកខ្មែរ ហើយម្យ៉ាងទៀត អរិយធម៌ខ្មែរពុំមែនទើបតែរីកដុះដាលឡើង នៅពេលទទួលអរិយធម៌ឥណ្ឌាប៉ុណ្ណោះទេ ពោលគឺជាអរិយធម៌មួយមានចំណាស់នៅក្នុងចំណោមអរិយធម៌ ដែលមានចំណាស់ជាងគេក្នុងពិភពលោក ហើយបានកើតឡើងនៅក្នុងអាស៊ីអាគ្នេយ៍ តាំងពីសម័យបុព្វប្រវត្តិសាស្ត្រដ៏យូរលង់ណាស់មកហើយ គឺតាំងពីមុនឥណ្ឌាចូលមកម្ល៉េះ។

លើសពីនេះទៅទៀតលោក **Maurice Glaize** ដែលជាអតីតអភិរក្សអង្គរបានសរសេរជាអាទិ៍ថាៈ ′Cenest nullement, comme certains le croient, un puremen tindinne qui ser air venu, a la suiote de migrations, se fixer dans ume region vide d′habitants, ou en aurait elements indigenes en masse: les people khmer est un people autochtone hindouise′ (មិនមែនដូចអ្នកខ្លះបានយល់នោះទេថាជាប្រជារាស្ត្រមួយ ដែលមានដើមកំណើតជាឥណ្ឌាសុទ្ធសាធ ហើយបានមកតាំងនៅក្នុងតំបន់មួយគ្មានមនុស្ស ឬក៏បានកំចាត់ពួកអ្នកស្រុកដោយសម្លាប់ ឬនិរទេសទាំងហ្វូង ប្រជារាស្ត្រខ្មែរ គឺជាអ្នកស្រុកដើមដែលបានទទួលឥទ្ធិពលអរិយធម៌ឥណ្ឌា)។

ឯលោក Henri Marchal ដែលជាអតីតអភិរក្សអង្គរបានសរសេរថាៈ ′le Cambodgien n′est pes de race hindoue, il est le resultat de nombreux croisements avec un fond malayo indonesien......′ ខ្មែរ មិនមែនជាពូជសាសន៍ឥណ្ឌាទេ នេះជាលទ្ធផលនៃការផ្សំកាត់ច្រើនជាមួយនឹងមេឡានីសេយាង-ឥណ្ឌាស៊ីយាង....)។

ចំណែកឯលោក **Philippe Devillers** ដែលជាអ្នកស្រាវជ្រាវបារាំងម្នាក់ទៀត បានសរសេរក្នុងសៀវភៅ L′Asie du SudEst ក្បាលទី២ថា «.....Khmers, peuple de meme souche ethnolinguistique que les Mons».......(ខ្មែរជាជនជាតិដែលមានឬសគល់ខាងជាតិសាសន៍ និងភាសាជាមួយនឹងជនជាតិមន)។

សរុបសេចក្តីមក យើងឃើញថាលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់លោក **Maurice Glaize** លោក **Henri Marchal** និង លោក **Philippe Devillers** ដូចបានរៀបរាប់រួចមកហើយគឺជា

ការគាំទ្រនូវទស្សនៈរបស់លោកអ្នកប្រាជ្ញទាំងឡាយ ដែលបានចាត់ទុកជាអំបូរខ្មែរ-មន ជាអំបូរពិសេសមួយ។

បើតាមឯកសារថ្មី ដែលបោះពុម្ពផ្សាយនៅសហរដ្ឋអាមេរិកនៅឆ្នាំ១៩៦៤ (Ethnic groups of mainland south- East Asia) អំបូរខ្មែរ-មនមានគ្នាទាំងអស់ ៧៦ ក្រុមរស់នៅចាប់ពីប្រទេសឥណ្ឌាភាគខាងកើតរហូតដល់សមុទ្រចិន ដោយកាត់តាមប្រទេសភូមា ប្រទេសថៃ ប្រទេសឡាវ ប្រទេសវៀតណាម និងសាធារណរដ្ឋខ្មែរ។ ក្នុងចំណោមជនជាតិខ្មែរ-មនទាំងឡាយ មានតែខ្មែរ និងមនទេដែលបានកសាងអរិយធម៌ខ្ពស់ជាងគេ ព្រោះម្យ៉ាងដោយ ហេតុជនជាតិទាំងនេះ បានទៅរស់នៅត្រង់វាលទំនាបនៃទន្លេធំៗដែលមានដីជាតិល្អ ដែលអាចប្រកប របរកសិកម្ម បានយ៉ាងប្រសើរ ហើយម្យ៉ាងទៀតដោយមានការប្រាស្រ័យទាក់ទងនឹងជនបរទេសថែមទៀតផង។ ជនជាតិខ្មែររស់នៅត្រង់វាលទំនាបនៃទន្លេមេគង្គ ឯជនជាតិមន រស់នៅត្រង់តំបន់មេណាម (ប្រទេសសៀម) និងតំបន់វាលទំនាបនៃទន្លេឥរាវតី (ប្រទេសភូមាសព្វថ្ងៃ)។ ចំណែកឯជនជាតិខ្មែរ-មនឯទៀតដែលរស់នៅតាមព្រៃភ្នំ ស្ទើរតែគ្មានទំនាក់ទំនងជាមួយគ្នាផងនោះក៏ឃើញថាគ្មានការរីកចម្រើនលូតលាស់ នៅទន់ខ្សោយសឹងតែគ្រប់វិស័យទាំងអស់។ ដោយហេតុនេះហើយបានជាអ្នកប្រាជ្ញលោកបានយកឈ្មោះពីរនេះគឺ**មន** និង**ខ្មែរ** សម្រាប់សម្គាល់អំបូរ ទាំងមូល គឺអំបូរខ្មែរមន ប៉ុន្តែខ្មែរយើងបានផ្លាស់ឈ្មោះនេះពី**មន-ខ្មែរ** មកជា**ខ្មែរមន**វិញព្រោះយើងយល់ថាខ្មែរ យើងជាធាតុសំខាន់ជាងគេ ព្រោះជាជនជាតិមួយមានគ្នាច្រើនជាងគេ ហើយ មានឋានៈប្រកបដោយឯករាជ្យ អធិបតេយ្យ និងអរិយធម៌ខ្ពង់ខ្ពស់ថែមទៀតផង។ គួរបញ្ជាក់ផងដែលថាការកែប្រែរួចមកហើយនេះ បានទទួការយល់ព្រមពីអង្គការយូណេស្កូ ក្នុងសម័យប្រជុំកាលពីខែតុលា-វិច្ឆិកា ឆ្នាំ១៩៧០ ហើយ។

ឈរលើមូលដ្ឋាននៃការស្រាវជ្រាវរបស់អ្នកប្រាជ្ញមួយចំនួន លោកបានលើកនូវភស្តុតាងដើម្បីជាសក្ខីភាពមកបញ្ជាក់ក្នុងការគាំទ្រនូវអំណៈអំណាងរបស់ខ្លួន ដែលថាខ្មែរពិតជាមានដើមកំណើតជាជាតិពិសេសមួយដែលស្ថិតក្នុងអំបូរ ខ្មែរមនពិតប្រាកដនោះមានដូចខាងក្រោមៈ

## ខ. ភស្តុតាងដែលបញ្ជាក់ថាខ្មែរជាជាតពិសេសមួយ:

### ១. សាសនា

មនុស្សជាន់ដើមជឿថាមនុស្សស្លាប់ទៅមិនសូន្យទេ គឺមានព្រលឹងទៅចាប់ជាតិថ្មីទៀត។ ពួកខ្មែរលើដែលរស់នៅលើខ្ពង់រាបសព្វថ្ងៃ ក៏នៅមានជំនឿបែបនេះដែរពួកនេះចែកព្រលឹងជាបី

ប្រភេទគឺ ព្រលឹងធំដែលចេញពីខ្លួនមនុស្ស៦ខែមុនពេលស្លាប់ ព្រលឹងតូចចេញនៅពេលស្លាប់ និងព្រលឹងខ្លះទៀតស្លាប់៦ខែហើយទើបព្រមចេញ(១៦)។ ដល់កាលណាមនុស្សស្លាប់ទៅគេយកទៅកប់ ហើយយកគ្រឿងប្រដាប់ដែលបុគ្គលនោះធ្លាប់ប្រើយកទៅកប់ជាមួយដែរ ដើម្បីទុកឲ្យប្រើប្រាស់តទៅទៀត។ ខ្មែរយើងសម័យឥឡូវ តែកាលណាមនុស្សស្លាប់គេតែងរៀបគ្រឿងបន្លងប្រគេនចំពោះព្រះសង្ឃ ដើម្បីបញ្ជូនឲ្យអ្នកស្លាប់នោះដែរ។ បើតាមការស្រាវជ្រាវរបស់បុព្វប្រវត្តិវិទូ មនុស្សជាន់ដើមនិយមបញ្ចុះខ្មោចក្នុងក្រឡ ឬក្រោមថ្មដុល(dolmen ឬ menhir)ដោយដាក់ឲ្យសពអង្គុយ។ ទម្លាប់នៅស្ថិតស្ថេររហូតមកដល់សព្វថ្ងៃៈ បើកាលណាមាននរជនស្លាប់ គេយកទៅដាក់ក្នុងកោដ្ឋដែលប្រហែលជាក្លាយមកពីក្រឡនោះហើយ ឯធាតុរបស់រាស្ត្រសាមញ្ញក៏គេយកទៅដាក់ក្នុងកោដ្ឋហើយបញ្ចុះក្នុងចេតិយដែរ។

ផលវិបាកសំខាន់ដែលហូរចេញពីជំនឿដែលថា មនុស្សស្លាប់ទៅមិនសូន្យគឺជំនឿលើខ្មោចអារក្សអ្នកតានេះឯង។ អ្នកតាជាព្រលឹងនៃជនដែលស្លាប់ទៅ ហើយតែនៅថែរក្សាមើលសុខទុក្ខដល់កូនចៅតទៅទៀត(បើជាស្រីគេហៅថាអ្នកដូន)។ខ្មែរយើងសព្វថ្ងៃនៅមានជំនឿលើអ្នកតាច្រើននៅឡើយ ជាពិសេសក្នុងចំណោមអ្នកស្រែចំការ ដោយខ្មែរយើងជឿថា អ្នកតាមានកំលាំងខ្លាំងពូកែណាស់ មានមហិទ្ធិរិទ្ធិអស្ចារ្យ។ អ្នកតាគឺជាបុព្វជនដែលជាអ្នកកាប់ឆ្ការព្រៃកសាងភូមិស្រុកដំបូងបង្អស់ មេកន្ទ្រាញ មេទ័ពខ្លាំងពូកែដែលបានស្លាប់ទៅក្នុងបុព្វហេតុជាតិ មាតុភូមិជាដើម។ អ្នកតាខ្លះមានខ្ទម រោង អាស្រម ជាលំនៅ អ្នកតាខ្លះគ្មានលំនៅទេ។ អ្នកតាមានឋានៈមិនស្មើគ្នាទេ មានជាន់ មានថ្នាក់តាមលំដាប់លំដោយ។ អ្នកតាខ្មែរនៅពាសពេញប្រទេសកម្ពុជាគ្រប់ច្រកល្ហក ដូចជាតាមវត្តអារាម វាលស្រែចំការ ព្រៃភ្នំក្រំថ្ម ទន្លេ ស្ទឹង បឹងបួ សមុទ្រ ដើមឈើធំៗ ទីទួលខ្ពស់ៗជាដើម។ អ្នកតានៅភូមិណាជាអ្នកទទួលបន្ទុកមើលការខុសត្រូវថែរក្សាភូមិនោះ។ បើអ្នកណាធ្វើអំពើមិនគប្បីទៅលើអ្នកតា អ្នកនោះនឹងទទួលទណ្ឌកម្ម។ ក្រោយពីសែនព្រេនរួចហើយគេក៏បានជាសះស្បើយឡើងវិញ។ អ្នកស្រុកចូលចិត្តទៅបន់ស្រន់អ្នកតា សុំឲ្យបានសុខសប្បាយ ឲ្យបានផលផ្លែផ្កាល្អ ឲ្យសត្វពាហនៈ ប្រាសចាកជំងឺ ឲ្យមានទឹកភ្លៀងគ្រប់គ្រាន់ កុំឲ្យសត្វស៊ីដំនាំ កុំឲ្យមានចំបាំង កុំឲ្យមានអសន្តិសុខជាដើម។ តំបន់ខ្លះគេធ្វើពិធីបុណ្យឡើងអ្នកតាប្រចាំឆ្នាំយ៉ាងគគ្រឹកគគ្រេង ដើម្បីសុំសេចក្តីសុខពីអ្នកតាជាដើម។ ពួកខ្មែរលើក៏មានជំនឿដូចគ្នានេះដែរ ហើយគេហៅអ្នកតាថា"ព្រះ"។ ដូច្នេះយើងឃើញថា ពួកអ្នកស្រុកមានទម្លាប់គោរព បូជាដូនតានេះស្រេចទៅហើយ នៅពេលឥណ្ឌាចូលមកដល់។ លុះលទ្ធិពុទ្ធសាសនានាំចូលមក ជំនឿដែលចាត់ថាមនុស្សស្លាប់ទៅមិនសូន្យ ព្រោះមានវិញ្ញាណទៅកកើតជារូបថ្មីទៀតក៏មានលក្ខណៈ

ប្រហាក់ប្រហែល និងជំនឿរបស់អ្នកស្រុកឲ្យ (ព្រលឹងហើយនឹងវិញ្ញាណមិនដូចបេះបិទទេ)ហើយក៏បានពួកនេះទទួលយកទៅ។ សព្វថ្ងៃនេះ បុណ្យភ្ជុំបិណ្ឌគឺជាបុណ្យសំយោគរវាងជំនឿបែបពុទ្ធសាសនា និងជំនឿរបស់អ្នកស្រុកឲ្យ។

មនុស្សជំនាន់ដើមមានជំនឿម្យ៉ាងទៀតថា កន្លែងសំរាប់គោរពបូជាគឺស្ថិតនៅលើកំពស់មានកំពូលភ្នំជាដើម។ គឺជំនឿបែបនេះហើយដែលបង្កើតឲ្យមានទស្សនៈឲ្យមានកសាងប្រាសាទភ្នំ: អេតណូវិទូខ្លះដូចជាលោក Quarit Ches WaTes បានពន្យល់ថាប្រាសាទភ្នំជាតំណាងភ្នំ ឯលិង្គតម្កល់ក្នុងប្រាសាទភ្នំគឺជាតួអ្នកតានេះឯង។

ជំនឿមួយទៀតរបស់អ្នកស្រុកដើមដែលគួរអោយកត់សំគាល់ដែរ គឺការគោរពទេព្ដាដីព្រោះដីជាមូលដ្ឋានផ្ដល់នូវស្រូវអង្ករជាអាហារសំខាន់។ ជំនឿនេះ គេឃើញមានរំលឹកឡើងវិញក្នុងពិធី "ច្រត់ព្រះនង្គ័ល" បើករដូវធ្វើស្រែចំការ។

## ២. ទំនៀមទំលាប់

ក្នុងវិស័យនេះមានការទុកស្រីជាធំក្នុងគ្រួសារ និងក្នុងសង្គម(Matriarcat) និងការរាប់ញាតិតាមខ្សែស្រឡាយ ខាងម្ដាយ(filiation en ligne maternelle)។ ចំពោះខ្មែរយើងគោលសំខាន់ខាងលើនេះ តែងបានបន្សល់នូវដានជាក់លាក់តាំងតែពីដើមរហូតមកដល់សព្វថ្ងៃ។ យ៉ាងណា មិញរឿងព្រេងដែលទាក់ទងនឹងការបង្កើតបឋមវង្ស ហើយដែលអ្នកប្រវត្តិសាស្ត្រចិនបានកត់ត្រាទុក (ហ៊ុនទៀន និងនាងលីវយី)បានបង្ហាញថាអ្នកដឹកនាំសង្គមខ្មែរក្នុងសម័យដើមមានភេទជាស្រី។

ឯសិលាចារឹកបានឲ្យពត៌មានថា នៅសម័យអង្គរស្រីមានអំណាចទុកដាក់ចែកចាយទ្រព្យសម្បត្តិគ្រួសារតាមចំណង់ចិត្តរបស់ខ្លួនដោយមិនបាច់សុំយោបល់ពីប្ដីទេចំណែកប្ដីវិញ បើចង់ធ្វើអំណោយត្រូវទទួលការយល់ព្រមពីប្រពន្ធជាមុន ឬបើពុំដូច្នោះទេទាល់តែបញ្ជាក់ថាទ្រព្យនោះជាទ្រព្យផ្ទាល់របស់ខ្លួនជាប្ដីឥតមានទាក់ទង និងប្រពន្ធទេ។ ម្យ៉ាងទៀត ការចែកកេរមត៌កតែងធ្វើតាមខ្សែស្រឡាយខាងស្រីជាដរាប: ការផ្ទេរងារជាព្រាហ្មណ៍មិនត្រូវផ្ទេរពីឪពុកទៅកូនទេ តែត្រូវផ្ទេរពីឪពុកមាទៅកូនប្រុសរបស់កូនស្រី ឬក៏ពីឪពុកមាទៅកូនប្រុសរបស់កូនស្រីនៃប្អូនស្រីរបស់ខ្លួន។ របបចែកកេរមត៌កដោយចាប់យកខ្សែស្រឡាយខាងម្ដាយជាធំ (matrilinéarité) ត្រូវគេយកទៅអនុវត្តក្នុងការផ្ទេររាជសម្បត្តិទៀត: សិលាចារឹកប្រែរូប(៩៦១)បានឲ្យដឹងថា ព្រះបាទរាជេន្ទ្រវរ្ម័នទី២ មានព្រះបិតាព្រះនាមមហេន្ទ្រវរ្ម័ន ដែលមានដើមកំណើតនៅភវបុរ (ចេនឡាដីគោក) ឯ

ព្រះមាតាព្រះនាមមហេន្ទ្រទេវីជាបងបង្កើតរបស់ព្រះបាទយសោវរ្ម័នទី១ ជាក្សត្រខាង សោមវង្ស ដោយហេតុនេះហើយទើបទ្រង់អាចទទួលរាជសម្បត្តិពីព្រះបាទហសិវរ្ម័នទី៤ ជាក្សត្រសោមវង្សបាន(១១)។ គួរកត់សំគាល់ថាមានរឿងព្រេងខ្មែរជាច្រើន បាននិទានពីការប្រកួតប្រជែងរវាងស្រី និងប្រុសក្នុងវិស័យផ្សេងៗ មានការជីកស្រះ ពូនភ្នំ សង់ប្រាសាទជាដើម ហើយទោះបីរឿងទាំងនោះបានបញ្ជាក់ថាភេទស្រីមានជ័យជំនះលើប្រុសក៏ដោយ ក៏សព្វថ្ងៃនេះសង្គមខ្មែរបានវិវត្តមកដល់ដំណាក់ការមួយដែលភេទស្រី ត្រូវបាត់បង់ឧត្តមភាពរបស់ខ្លួនទៅលើភេទប្រុសទៅហើយ។ ក៏ប៉ុន្តែសង្គមនេះនៅរក្សាដានខ្លះល្មមឲ្យយើងជឿបាននូវអត្ថិភាពរបស់ទស្សនៈទុកស្រីជាធំនៅឡើយ។ យ៉ាងណាមិញ របស់ ឬមនុស្សដែលមានភាព ឬតួនាទីជាធំចំបងលើគេឯងទៀត ខ្មែរយើងនៅតែហៅថា **មេ** ដូចជាមេដៃ មេជើង មេដំបូល មេដែក មេទ័ព មេឃុំ មេស្រុក មេគយ មេការ។ល។ ក្នុងការស្ដីដណ្ដឹងគូស្រករត្រូវប្រុសចូលទៅនិយាយ សុំសេចក្ដីយល់ព្រមពីខាងស្រី លុះដល់ពេលរៀបការក៏ខ្មែរយើងនិយមទៅធ្វើផ្ទះខាងស្រីទៀត។ ហើយភស្ដុតាងដែលជាក់ស្ដែងជាងនេះទៅទៀត គឺពាក្យស្លោកខ្មែរមួយវគ្គដែលបានចែងថា "សូវស្លាប់បាកុំឲ្យស្លាប់មេ សូវលិចទឹកកណ្ដាលទន្លេ កុំឲ្យភ្លើងឆេះផ្ទះ។

ដោយអាងទៅលើគោលធំមួយនៃអរិយធម៌ខ្មែរ គឺការទុកស្រីជាធំក្នុងគ្រួសារ និងក្នុងសង្គមនេះហើយ ទើបយើងយល់ថា **ខ្មែរ** ទំនងជាក្លាយមកពី **ក + មេ** ដូចមានការវិវត្តន៍ដូចតទៅនេះ ៖

**ក + មេ > កមេ > ក្មេ > ក្មេរ៑ > ខ្មេរ៑ > ខ្មែរ**

~ ក្នុងភាសាខ្មែរព្យញ្ជនៈ "**ក**" ជាបុព្វបទមួយមួយសំរាប់ធ្វើន័យរបស់ពាក្យណាមួយ ឲ្យមានលក្ខណៈកាន់ តែខ្លាំងក្លាឡើង។ **ឧទាហរណ៍:** កកាយ(កាយញាប់ជាងធម្មតា) កកូរ(កូញាប់ជាងធម្មតា) កខឹក(សោច ឮខឹកៗ ញាប់ជាងធម្មតា)។

~ មេ សំគាល់ស្ត្រីជាម្ដាយនៅក្នុងគ្រួសារឬស្ត្រីជាអ្នកដឹកនាំនៅក្នុងសង្គម។

~ ក្មេរ៑ បានន័យថា អ្នកគោរពមេ គឺអ្នកធ្វើអោយមេមានលក្ខណៈកាន់តែច្បាស់ឡើង។ពាក្យនេះមានប្រើនៅក្នុងសិលាចារឹកមុនសម័យអង្គរ ដូចជានៅសិលាចារឹកប្រាសាទជាន់ជុំជា ដើម។

~ ខ្មេរ៑ ក្លាយមកពីក្មេរ៑ទៀតគឺ "ក" ក្លាយមកជា "ខ"។ ពាក្យនេះមានប្រើនៅសម័យអង្គរ ក្នុងសិលាចារឹកប្រាសាទបន្ទាយឆ្មារជាដើម គឺនៅពេលដែលខ្មែរយើងបានបង្កើតតួ "ខ" សំរាប់ សរសេរពាក្យបាលីសំស្ក្រឹត។

~ ខ្មៅវិក្លាយមកពីខ្មែរនេះទៀត ដូចជាម៉ែដែលបានក្លាយមកពីមេដូច្នោះដែរ។

ដើម្បីជាការប្រៀបធៀប គួរគប្បីជ្រាបថាជនជាតិឥណ្ឌានិងជនជាតិចិន ដែលធ្លាប់តែជះឥទ្ធិពលរបស់ខ្លួនមកលើ ជាតិខ្មែរយើងនោះ គេមិននិយមទុកស្ត្រីជាធំដូចខ្មែរយើងទេ តែផ្ទុយទៅវិញគឺគេទុកប្រុសជាធាតុមានតម្លៃជាងស្រី។

ចំពោះជនជាតិឥណ្ឌាគេដឹងថា តាំងតែពីព្រេងនាយមកស្រីមេម៉ាយពុំមានសិទ្ធយកប្ដីថ្មីទៀតឡើយៈ កាលណាប្ដីស្លាប់ទៅ ស្រីឥណ្ឌាត្រូវនៅបំរើគ្រួសារប្ដីតទៅទៀត ឬមួយលោតទៅក្នុងភ្លើងស្លាប់តាមប្ដីដើម្បីជៀសអោយផុតពីលំបាកវេទនាក្នុងការរស់នៅ(15)។ ម្យ៉ាងទៀតពាក្យ **ប្ដី** ដែលក្លាយមកពីពាក្យ **បតិ** (=ម្ចាស់) ក៏អាចបង្ហាញឲ្យឃើញថាជនជាតិឥណ្ឌាមានទស្សនៈខុសឆ្ងាយពីខ្មែរណាស់។

ចំណែកឯក្នុងសង្គមចិនវិញ គេឃើញមានការគោរពបូជាដូនតា។ក្នុងគ្រួសារនីមួយៗ គឺប្ដីជាអ្នកមានមុខងារសំខាន់ ក្នុងការទទួលខុសត្រូវធ្វើយ៉ាងណា ឲ្យការគោរពបូជានេះអាចប្រព្រឹត្តទៅដោយគ្មានឧបសគ្គ។ បើឪពុកស្លាប់ទៅ គឺកូនប្រុសច្បងនេះហើយដែលត្រូវទទួលតំណែងសំខាន់ខាងលើជំនួសឪពុក ឯកូនស្រីគ្មាននាទីបន្តិចបន្តួចសោះឡើយ ក្នុងបន្ទុកនោះ។ ហេតុនេះហើយបានជាជនជាតិចិន មិនឲ្យតម្លៃទៅលើកូនស្រីទេៈ តែកាលណារៀបការហើយ គេតែងបញ្ជូនឲ្យទៅនៅគ្រួសារខាងប្រុស។ បើកាលណាប្ដីស្លាប់ ត្រូវនៅបំរើគ្រួសារខាងប្ដីតទៅ ទៀត។ តាមទម្លាប់ចិន កូនស្រីបើមិនទាន់មានប្ដីត្រូវស្ដាប់បង្គាប់ឪពុក បើមានប្ដីត្រូវស្ដាប់បង្គាប់ប្ដី ហើយបើផុតពីប្ដីទៅ ត្រូវស្ដាប់បង្គាប់កូនប្រុសច្បង (régle des trois soumissions )។ គួរកត់សម្គាល់ម្យ៉ាងទៀតថា ជនជាតិចិននិយមឲ្យតម្លៃទៅញាតិខាងឪពុកៈ **ឧទាហរណ៍ៈ** ដូចជាជីដូនជីតាខាងឪពុកគេហៅថា **ជីដូនជីតាក្នុង** ឯជីដូនជីតាខាងម្ដាយគេហៅថា **ជីដូនជីតាក្រៅ** (ក្នុងគឺក្នុងរង្វង់គ្រួសារ ក្រៅ គឺក្រៅរង្វង់គ្រួសារគេមិនសូវរាប់រកទេ)។

## ៣. ភាសា និងអក្សរ

### ៣.១.ភាសា

ភាសា គឺជាពាក្យសម្ដីដែលយើងនិយាយប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក រឺជាការសម្ដែងនូវសកម្មភាព ដើម្បីសម្ដែងនូវឆន្ទៈ សញ្ចេតនា ចិត្តគំនិត្តអ្វីមួយ។

### ៣.១.១. ការវិវត្តន៍ភាសា

នៅក្នុងលោកយើងនេះ គ្រប់ជាតិសាសន៍សុទ្ធតែមានភាសាផ្ទាល់របស់ខ្លួនសម្រាប់ប្រើទាក់ទងគ្នានៅក្នុងសង្គមជាតិរៀងៗខ្លួន។ ភាសានៃជាតិសាសន៍នីមួយៗមានកំណើតឡើងដំណាលគ្នានឹងកំណាកំណើតនៃជាតិសាសន៍នោះដែរ ហើយបានវិវត្តិប្រែប្រួលចម្រើនលូតលាស់ ឬអន់ថយទៅតាមសង្គមមនុស្សថែមទៀតផង។

តាមប្រវត្តិសាស្ត្រមនុស្សលោក ភាសាកើតមុនអក្សរជាយូរអង្វែងណាស់។ ភាសាកើតឡើងដំណាលនឹងកំណើតមនុស្ស។ ភាសាកើតឡើងហើយប្រែប្រួលតាមតម្រូវការ និងការចាំបាច់របស់សង្គម។ វាប្រែប្រួលផ្លាស់ប្តូរតាមច្បាប់ពិតរបស់ខ្លួន។ ភាសាជាកញ្ចក់ពិសេសសម្រាប់ឆ្លុះមើលចិត្តគំនិត ទស្សនៈ មនោគមវិជ្ជា វប្បធម៌អរិយធម៌ របៀបរស់នៅនៃជនជាតិនីមួយៗ។ ភាសាស្ថិតជាប់នឹងសង្គម ឬជាតិ បើសង្គម ឬជាតិរីកចម្រើន ភាសាក៏រឹងប៉ឹងលូតលាស់ តែផ្ទុយបើសង្គម ឬជាតិទន់ខ្សោយ រខេករខាកវិញនោះភាសាក៏ទន់ខ្សោយ និងរខេករខាកដែរ។ ភាសានេះធំធាត់រីកចម្រើន ឬអន់ថយរហូតដល់ស្លាប់ដូចមនុស្សដែរ។ ការប្រែប្រួលនេះធម្មតាធ្វើឡើង ក្នុងរយៈពេលច្រើនឆ្នាំពុំមែនប្រែប្រួលរហ័សក្នុងថ្ងៃនេះ ឬថ្ងៃស្អែកឡើយ។ ធម្មតាការវិវត្តិភាសាយើងមើលពុំដឹងទេ។ ដូចមនុស្សយើងប្រែប្រួលរាល់ថ្ងៃ កើតធំចាស់ដោយមិនដឹងខ្លួនដូចនោះដែរ។

ភាសាអាចស្លាប់ អាចរលាយទៅជាផង់ធូលី ឬនៅសល់តែគំនរឆ្អឹងដែលពិបាកនឹងប្រមូលយកមកផ្គុំឲ្យមានជីវិតឡើងវិញណាស់ អដ្ឋិសង្ខលិកឥតជីវិតគេគ្រាន់តែតម្កល់ទុកសម្រាប់ឲ្យមនុស្សជំនាន់ក្រោយពិនិត្យតែប៉ុណ្ណោះ។ ភាសាវិវត្តតាមធម្មជាតិស្របតាមដំណើរច្បាប់របស់ភាសា។ គេពុំអាចបង្ខំពត់ភាសាឱ្យទៅតាមទិសនេះ ឬទិសនោះបានទេ បើពត់បានគឺកម្របំផុត។ ភាសារស់បានដោយមានក្បួនងាយស្រួលហើយមានលក្ខណៈប្រជាប្រិយ។

### ៣.១.២. អំបូរភាសា

គ្រប់ជនជាតិទាំងអស់ សុទ្ធតែមានភាសាផ្ទាល់របស់ខ្លួន សំរាប់ធ្វើទំនាក់ទំនងគ្នានៅក្នុងសង្គមជាតិរៀងៗខ្លួនភាសានីមួយៗមានកំណើតដំណាលគ្នា នឹងកំណើតនៃសាសន៍នោះដែរ ហើយបាន វិវត្តរីកចំរើនលូតលាស់ ឬអន់ថយទៅតាមដំណើរវិវត្ត នៃសង្គមនោះថែមទៀតផង។ ភាសាវិទូបានសិក្សាស្រាវជ្រាវអំពីភាសាទាំងអស់នៅក្នុងលោកឃើញថាភាសាមានចំនួនច្រើនណាស់ បើរាប់ទាំងភាសាតូច ធំស្លាប់ រស់មានចំនួនពីពីរពាន់ប្រាំរយទៅបីពាន់ប្រាំរយភាសា។ ក្នុងចំណោមភាសាទាំងនោះភាសាវិទូបានធ្វើប្រភេទវិភាគចែកភាសាជាក្រុម ឬអំបូរ។

ភាសាដែលអាចស្ថិតនៅក្នុង អំបូរជាមួយគ្នាបានលុះត្រាតែមានលក្ខណៈពិសេសប្រហែលៗគ្នា។ អំបូរភាសាធំៗមានចំនួន២០តែយើងលើកយកមកបង្ហាញ មួយចំនួនដូចជា:

~ **អំបូរឥណ្ឌូរ-អឺរ៉ុប** គឺជាអំបូរភាសាមួយ ទូលំទូលាយក្នុងបណ្តាអំបូរភសាក្នុងលោក គ្របដណ្តប់លើទ្វីបអឺរ៉ុបជិតតែទាំងអស់ និងលើមួយភាគធំនៃប្រទេសឥណ្ឌា។

~ **អំបូរខ្មែរ-មន** គឺជាអំបូរសំខាន់មួយដែលនៅទ្វីប អាស៊ីអាគ្នេយ៍។

~ **អំបូរម៉ាឡាយ៉ូ-ប៉ូលីណេស៊ី** គឺជាអំបូរធំគួរសមស្ថិតនៅតាមកោះ និង នៅ ទៀបកោះ ក្នុងភាគខ្លះនៃមហា សមុទ្រ ប៉ាស៊ីហ្វិក និង មហាសមុទ្រឥណ្ឌា។

ភាសាខ្មែរស្ថិតនៅក្នុងអំបូរខ្មែរ-មន។ អំបូរនេះបែកចេញមកពីអំបូរធំមួយទៀតគឺ អំបូរអូស្រ្តូអាស៊ី។

អំបូរអូស្រ្តូអាស៊ីមាន ៖ ១.មុណ្ឌា ២.ខ្មែរមន ៣.នីកូបា ៤.មលក្កា ៥.វៀត-មឿង

**អំបូរខ្មែរ-មន** បែកចេញពីអំបូរ អូស្រ្តូអាស៊ីមាន ៖ ១.ក្រុមព័រ ២.ខ្មែរ ៣.ក្រុមបាណាង ៤.ក្រុមហ្ម ៥.ក្រុមកាទុ ៦.មន ៧.ក្រុមប៉ាឡោង ៨.ខាសិ។ នៅក្នុងក្រុមនីមួយៗខាងលើមានជនជាតិមួយចំនួនទៀតរស់នៅក្នុងក្រុមនោះមានដូចជា:

១. ក្រុមព័រមាន៖ ព័រ ជង សម្រែ ស្អូច.....

២. ខ្មែរមាន៖ ខ្មែរបុរាណ សុរិន បាសាក់.....

៣.ក្រុមបាណាងមាន៖ បាណាង សេដង់ ស្ទៀង ម្នង....

៤. ក្រុមហ្មមាន៖ ខ្មុរ ខាវ ខា.......

៥. ក្រុមកាទុមាន៖ កាទុ ព្រុ គួយ....

៦. មនមាន៖ មនបុរាណ មនតាំង......

៧.ក្រុមប៉ាឡោងមាន៖ ប៉ាឡោ វ៉ា ល្វះ......

### ៣.១.៣. ប្រវត្តនៃភាសាខ្មែរ

ដូចយើងបានពោលរួចមកហើយថា ភាសាមានកំណើតដំណាលគ្នានឹងកំណើតមនុស្ស។ យ៉ាងណាមិញ ប្រវត្តិសាស្រ្តខ្មែរបានចែងថា ជាតិសាសន៍ខ្មែរមានយូរយារណាស់មក

ហើយ (ប្រមាណ ៣០០០ឆ្នាំមុនគ.ស) គឺជាជាតិសាសន៍ដែលធ្លាប់មានអរិយធម៌រុងរឿងក្នុងចំណោមជាតិសាសន៍ដទៃក្នុងភូមិភាគអាស៊ីអាគ្នេយ៍។ ដូចនេះភាសាខ្មែរដែលមានប្រភពជាប់គ្នានឹងជាតិកំណើតមនុស្សខ្មែរក៏កើតមានតាំងពីយូរណាស់មកហើយដែរ។ ក្រោយដែលបានសិក្សាស្រាវជ្រាវអំពីភាសាខ្មែរអស់ពេលជាយូរមក ភាសាវិទូបរទេសបានបញ្ចូលភាសានេះ ទៅក្នុងអំបូរភាសាធំមួយក្នុងចំណោមអំបូរភាសា នៅទ្វីបអាស៊ី អាគ្នេយ៍ គឺអំបូរខ្មែរ-មន នេះឯង។ តាមលោកពីណូវ H.j.pinnow អំបូរភាសាខ្មែរ-មន ជាអំបូរក្រុមភាសាមួយដែលគួរអោយចាប់អារម្មណ៍ជាងគេក្នុងបណ្តាភាសាអាស៊ី ភាគខាងត្បូង (អំបូរភាសាអូស្ត្រូអាស៊ីៈ អំបូរភាសាម៉ាឡាយូប៉ូលីនេស៊ី អំបូរភាសាថៃ វៀតណាម អំបូរខ្មែរមន) ព្រោះជាអក្សរដែលមានប្រវត្តិប្លែកពីភាសាដទៃទៀតដែលទើបតែមានភាសាសរសេរហើយខ្លះទៀតនៅតែគ្មានអក្សរសរសេរដដែល។

ចំពោះពាក្យខ្មែរមននេះធ្វើឱ្យយើងមានចម្ងល់តទៅទៀតថាតើមនជាអ្វី?ហើយនៅឯណា?តើមានជាតិសាសន៍ខ្មែរ និងមនពីរនេះទេ ឬដែលនៅក្នុងអំបូរនេះ?

តាមការស្រាវជ្រាវ គេបានដឹងថា នៅក្នុងអំបូរខ្មែរ-មន ពុំមែនមានតែជាតិខ្មែរ និងជាតិមនប៉ុណ្ណោះទេ គឺមានជាតិជាច្រើនទៀតដែលរស់នៅក្នុងប្រទេសនានានៃអាស៊ីអាគ្នេយ៍ ហើយដែលមានភាសាស្រដៀងគ្នាក្នុងផ្នែក**សូរសាស្ត្រ**(La phonetique) **រូបសាស្ត្រ**(La morphologie) និង**និយណ្តសាស្ត្រ** (La semantique)។ ឯជនជាតិទាំងនោះមានជាអាទិ៍ៈ

~ សេណូយសេម៉ាង....នៅសហាពន្ធម៉ាឡេស៊ីយ៉ា
~ ប៉ាឡោង វ៉ា...នៅប្រទេសភូមា
~ ខ្មុ អាឡាក់ ល្មិត....នៅប្រទេសឡាវ
~ ស្ទៀង កួយ ព័រ ស្អូច ជង ព្នង....នៅសាធារណរដ្ឋខ្មែរ
~ ម្នង បាហ្នារ សេដង់ ព្រុ ....នៅប្រទេសវៀតណាម។

ក្នុងចំណោមជនជាតិទាំងនោះ មានតែជនជាតិខ្មែរ និងមនទេដែលមានអរិយធម៌ខ្ពស់ជាងគេ ពីព្រោះជនជាតិទាំងពីរនេះមានអរិយធម៌វប្បធម៌ខ្ពង់ខ្ពស់ជាងគេ។ ដោយហេតុតែអរិយធម៌ខ្មែរ និងមនលូតលាស់រុងរឿងនេះហើយទើបគេនិយមប្រើពាក្យមន-ខ្មែរ(តាមទស្សនៈអ្នកប្រាជ្ញបរទេស)ឬខ្មែរ-មន (តាមទស្សនៈខ្មែរ) ដូចពាក្យអំបូរខ្មែរ-មន អរិយធម៌ខ្មែរ-មនជាដើម។

ប៉ុន្តែចាប់ពីស.វទី១៦មកជនជាតិមនក៏បាត់បង់ទឹកដី និង អធិបតេយ្យរបស់ខ្លួនរហូតមក ដូចជនជាតិចាមសព្វថ្ងៃនេះដែរ។

### ៣.១.៤. វិវត្តន៍នៃភាសាខ្មែរ

ភាសាក៏ដូចជាធាតុឯទៀតៗនៃអរិយធម៌ដែរ តែប្រែប្រួលចម្រើនលូតលាស់ ឬអន់ថយស្របតាមការរស់នៅរបស់មនុស្សក្នុងសង្គម។ គេបានកត់សម្គាល់ឃើញថា ភាសាសរសេរវិវត្តពុំទាន់ភាសានិយាយទេ។

ចំពោះកំណាកំណើតភាសាខ្មែរដែលមានជីវិតរហូតមកដល់សម័យបច្ចុប្បន្ននេះ អ្នកប្រាជ្ញខាងភាសាបានសង្កេតឃើញ មានការវិវត្តន៍៣លើកធំៗគឺៈ

~ ភាសាខ្មែរបុរាណ (តាំងពីកំណាកំណើតមកដល់ស.វ.ទី១៥)
~ ភាសាខ្មែរកណ្ដាល (ស.វ.ទី១៦ ដល់ ស.វទី១៩)
~ ភាសាខ្មែរបច្ចុប្បន្ន (ស.វ.ទី២០...)។

នៅសម័យអាណាព្យាបាលបារាំង វិវឌ្ឍន៍នៃភាសាខ្មែរត្រូវបានបន្ថយល្បឿនហើយរត់ទៅសម្ងំក្នុងវត្តអារាមដែលមានព្រះសង្ឃជួយថែរក្សាទុកអោយ។ គេបង្ខំអោយរៀនភាសាបារាំងជាយាន ជាផ្លូវការណ៍ដែលជាហេតុនាំឱ្យខូចប្រយោជន៍ដល់ភាសាជាតិនេះឯង។

នៅសម័យឯករាជ្យ ភាសាខ្មែរត្រូវបានប្រកាសឱ្យប្រើជាផ្លូវការ។ កំណើតគណៈកម្មការមហាវិទ្យាល័យគរុកោសល្យ(អតីតវិទ្យាស្ថានជាតិគរុកោសល្យ) មហាវិទ្យាល័យអក្សរសាស្ត្រ វិទ្យាស្ថានជាតិខេមរយានកម្ម ជម្រុញឱ្យមានការបង្កើតពាក្យពេចន៍ថ្មីៗជាច្រើនទៀត ដើម្បីប្រើការឱ្យទាន់សម័យនិយម។ ក្រៅពីពាក្យកំណើត ពាក្យបង្កើតថ្មី គេប្រទះឃើញពាក្យបរទេសជាច្រើន នៅលាយឡំក្នុងភាសាខ្មែរ។

ឯភាសានេះកើតឡើងនៅពេលដែលខ្មែរមានទំនាក់ទំនងជាមួយបរទេស ដូចជាទាក់ទងក្នុងកិច្ចការទូតទេសចរណ៍ ពាណិជ្ជកម្ម សិក្សាអប់រំ ជំនឿសាសនា។ល។ គេបានកត់សម្គាល់ឃើញថាភាសាមានអាយុវែងកាលណាល្បាយភាសាកាន់តែមានច្រើនឡើងៗ សឹងរកភាពសុទ្ធរបស់ខ្លួនពុំឃើញ។ ឯភាសាបរទេសដែលនៅលាយឡំច្រើនជាងគេក្នុងភាសាខ្មែរយើងសព្វថ្ងៃគឺ ភាសាបាលី និង សំស្ក្រឹត។ ភាសាបាលីហូរមកចូលក្នុងភាសាខ្មែរតាមរយៈពុទ្ធ

សាសនា ហីនយាន ឯភាសាសំស្ក្រឹតហូរចូលតាមរយៈពុទ្ធសាសនាមហាយាន និងព្រាហ្មណ៍សាសនា ដោយជនជាតិខ្មែរយើងនិយមគោរពសាសនាឥណ្ឌា ទាំងនេះហើយបានជាភាសាសំស្ក្រឹត ព្រមទាំងក្បួនខ្នាតវេយ្យាករណ៍មានឥទ្ធិពលខ្លាំងក្លាមកលើភាសាខ្មែរ ហើយចាក់រឹសមកដល់សព្វថ្ងៃ ជាហេតុនាំឱ្យ អ្នកខ្លះដែលមើលលក្ខណៈដើមនៃភាសាខ្មែរពុំឃើញ ហើយក៏តាំងចោទថាភាសាខ្មែរមានប្រភពមកពីភាសាបាលី សំស្ក្រឹតនេះឯង។ ការពិត ភាសាទាំងពីរនេះចូលមកក្រោយពេលដែលខ្មែរមានភាសាផ្ទាល់ ខ្លួនរួចស្រេចមកហើយ។ ដូចនេះភាសាខ្មែរពុំមែនកើតចេញមកពីភាសាបាលី សំស្ក្រឹត ឬភាសាបាលីសំស្ក្រឹតជាម្តាយ នៃភាសាខ្មែរ ដូចទស្សនៈរបស់លោក J. Taupin នោះទេ។ ខ្មែរប្រើពាក្យ បាលី-សំស្ក្រឹត ជាពាក្យកម្ចី ដើម្បីបង្គ្រប់ នូវកង្វះខាត តែប៉ុណ្ណោះ។ រីឯពាក្យបាលីសំស្ក្រឹតនេះទៀតសោត ក៏ត្រូវកែប្រែទាំងសូរស័ព្ទទាំងរូបស័ព្ទដើម្បីអោយស្របស្រួលនឹងសម្តីខ្មែរ ចំណង់ចំណូលចិត្តរបស់ខ្មែរ។ ខេមរនីយកម្មបែបនេះពុំមែនធ្វើចំពោះតែពាក្យបាលី-សំស្ក្រឹតប៉ុណ្ណោះទេ ភាសាបរទេសណាក៏ដោយ ដែលជ្រាបចូលមកក្នុងភាសាខ្មែរត្រូវទទួលការផ្លាស់ប្តូរអោយមានលក្ខណៈជាខ្មែរដែរ។ ម្យ៉ាងទៀត ភាសាបាលី-សំស្ក្រឹតស្ថិតដាច់អំពីអំបូរខ្មែរ-មន ព្រោះមានវិភត្តិដូចភាសានៃជនជាតិអឺរ៉ុបដែរ។ ដូចនេះភាសាបាលី-សំស្ក្រឹតនៅក្នុងអំបូរឥណ្ឌូ-អឺរ៉ុបឯណោះទេ។

### ៣.១.៥. ការសម្គាល់ពាក្យកម្ចីបាលី សំស្ក្រឹតនៅក្នុងភាសាខ្មែរ

គេអាចសម្គាល់ពាក្យកម្ចីបាលីសំស្ក្រឹតមួយចំនួននៅក្នុងភាសាខ្មែរ ដូចខាងក្រោមនេះ ៖

១. ពាក្យដែលមានប្រើយុគលពិន្ទុ "ះ" **ឧទាហរណ៍** ៖ រយៈ ឆន្ទៈ លក្ខណៈ ទុក្ខៈ...។
២. ពាក្យដែលមានប្រើសញ្ញាបដិសេធ "៍" **ឧទាហរណ៍**៖ អនុវត្តន៍ របាយការណ៍...។
៣. ពាក្យដែលមានប្រើសំយោគសញ្ញា "័" **ឧទាហរណ៍** ៖ សម័យ វិស័យ....។
៤. ពាក្យដែលមិនប្រើសញ្ញាបន្តក់ "់" **ឧទាហរណ៍**៖ នរក ប្រជាជន...។
៥. ពាក្យដែលមិនប្រើសញ្ញារបាទ "៌" **ឧទាហរណ៍**៖ ពិត៌មាន ពណ៌...។
៦. ពាក្យដែលមិនប្រើសញ្ញាលេខទោ "ៗ" **ឧទាហរណ៍**៖ នានា។
៧. ពាក្យដែលប្រកបនឹងព្យញ្ជនៈ "ទ" **ឧទាហរណ៍**៖ គូទ អត្ថបទ...។
៨. ពាក្យដែលប្រកបនឹងព្យញ្ជនៈ"ណ" **ឧទាហរណ៍**៖ ប្រាណ គុណ...។
៩. ពាក្យដែលប្រកបនឹងព្យញ្ជនៈ "គ" **ឧទាហរណ៍**៖ នាគ ភាគ....។

១០. ពាក្យដែលប្រកបនឹងព្យញ្ជនៈ "ឌ" **ឧទាហរណ៍៖** មាឌ គ្រុឌ...។

១១. ពាក្យដែលប្រកបនឹងព្យញ្ជនៈ "ព" **ឧទាហរណ៍៖** ភាព ទេព...។

១២. ពាក្យដែលប្រកបនឹងព្យញ្ជនៈត្រួតជើង **ឧទាហរណ៍៖**ទ្រព្យ ពេទ្យ....។

១៣. ពាក្យដែលប្រកបនឹងព្យញ្ជនៈត្រួតជើង បូកស្រៈ **ឧទាហរណ៍៖** សម្បត្តិ ប្រតិបត្តិ...។

១៤. ពាក្យដែលប្រកបនឹងព្យញ្ជនៈបូកស្រៈ **ឧទាហរណ៍៖** ហេតុ មតិ...។

### ៣.១.៦. លក្ខណៈពិសេសនៃភាសាខ្មែរ

ដើម្បីបំផុសឱ្យឃើញលក្ខណៈពិសេសនៃភាសាខ្មែរ និងដើម្បីកុំឱ្យមានការយល់ច្រឡំដូចទស្សនៈខាងលើទៅទៀត យើងសូមធ្វើការប្រៀបធៀបចំណុចសំខាន់ៗខ្លះនៃភាសាខ្មែរទៅនឹងភាសាខ្លះទៀតជាពិសេសភាសាបាលី-សំស្ក្រឹត។

**១. ការបន្លឺសម្លេង៖** ក្នុងការបន្លឺសម្លេងពាក្យខ្មែរក្តី មនក្តី ពុំមានសម្លេងឡើងចុះ ឬលើកដាក់ខ្ពស់ទាបទៅតាមសញ្ញាប្រើដាក់លើពាក្យ ដែលនាំឱ្យផ្លាស់ប្តូរន័យរបស់ពាក្យនោះទេ។ នេះជាចំណុចសំខាន់មួយដែលបង្ហាញនូវសភាពប្លែកគ្នារវាងភាសាខ្មែរ-មន និងក្រុមភាសាចិន យួន សៀម ឡាវ ដែលជាភាសាភ្ជាប់ន័យទៅនឹងសម្លេងខ្ពស់ទាប ឬ ចុះឡើង។ ឧទាហរណ៍ ៖

~ នៅក្នុងភាសាចិន ៖ mā=ម្តាយ má=ធ្មៃ ma=សេះ mà= ជេរ

~ នៅក្នុងភាសាវៀតណាម ៖ ma=ខ្មោច má=ដើម្បី mà=សេះ

ដូចនេះភាសាវៀតណាមក្តី ចិន ក្តី សុទ្ធតែបានភ្ជាប់ន័យទៅនឹងសម្លេងឡើងចុះខ្ពស់ទាបជានិច្ច។

**២. ចំនួនព្យាង្គ៖** ពាក្យខ្មែរសុទ្ធច្រើនមានចំនួនព្យាង្គតិចគឺសម្បូណ៌ពាក្យមួយព្យាង្គ ប្លែកអំពីពាក្យបាលី-សំស្ក្រឹតដែលច្រើនតែមានចំនួនព្យាង្គច្រើន។ ក្នុងករណីពាក្យខ្មែរសុទ្ធ២ព្យាង្គ ឬច្រើនព្យាង្គ គេបានសង្កេតឃើញថាការបន្លឺសម្លេងតែងមានទំនោរទៅរកការបង្រួញព្យាង្គច្រើនឱ្យនៅសល់តិចបំផុតដោយបន្ធើរ ស្ទួរ ឬបង្រួញស្នូរនៅព្យាង្គមុខ ហើយសង្កត់ស្នូរនៅព្យាង្គ ដូចពាក្យ ៖

ប្រអប់ > ប្អប់ បបរ > ប្បរ សៀវភៅ > សភៅ
ក្រមា > កមា ជណ្តើរ > ជ្តើរ ត្របែក >តបែក។ល។

ទំនោរបង្រួញព្យាង្គនេះ មានឥទ្ធិពលយ៉ាងខ្លាំង ទៅលើពាក្យបាលី-សំស្ក្រឹត ដែលចូលមកលាយឡំក្នុងភាសាខ្មែរហើយដែលមានចំនួនព្យាង្គដូចពាក្យ ៖

- ជាតិ [ ជាត តិ ] អានជាត ⇨ ២ ព្យាង្គនៅសល់១ព្យាង្គ
- ទុក្ខៈ [ ទុក ខៈ] អានទុក ⇨ ២ ព្យាង្គនៅសល់១ព្យាង្គ
- និរន្តរៈ [ និ រាន់ តៈរៈ] អាននិរាន់ ⇨ ៤ ព្យាង្គនៅសល់២ព្យាង្គ
- សមាធិ [សៈ ម៉ា ធិ ] ក្លាយទៅជាស្មាធិ៍ ⇨ ៣ ព្យាង្គនៅសល់១ព្យាង្គ
- អជាសុក [ អៈជា សុកៈ] ក្លាយទៅជាអផ្សុក ⇨ ៤ ព្យាង្គនៅសល់២ព្យាង្គ
- ចតុរង្គ [ ចៈតុ រ៉ង គៈ] ក្លាយទៅជាចត្រង្គ ⇨ ៤ ព្យាង្គនៅសល់២ព្យាង្គ

នៅមានវិធីច្រើនបែបយ៉ាងទៀតដែលខ្មែរយកមកអនុវត្ត ដើម្បីកែប្រែ ឬបង្រួញព្យាង្គបាលី-សំស្ក្រឹតឱ្យមានលក្ខណៈបែបខ្មែរឡើង (ខេមរនីយកម្មចំនួនព្យាង្គ)។ លក្ខណៈកែប្រែនេះសឱ្យឃើញថាខ្មែរពុំមែនចេះតែទទួលយកពាក្យបរទេសមកប្រើទាំងស្រុងទេ។

**៣. អំពីស្រៈ ព្យញ្ជនៈ ព្យាង្គ**

~ **មូលភេទអ-អ៊** នៅក្នុងភាសាខ្មែរយើងមានមូលភេទធំពីរ គឺ**អ-អ៊**។ មូលភេទ **អ-អ៊** នេះជាមេខ្យល់ក្នុងភាសាខ្មែរយើង។ ភាសាមនគេចែកជាខ្យល់ **អ-អេ** ឯភាសាបាលីសំស្ក្រឹតមានខ្យល់ **អៈ**មួយទេ។

~ សញ្ញាព្យញ្ជនៈក្នុងភាសាខ្មែរមានពីរពួកគូរៗគ្នា ខុសពីសញ្ញាព្យញ្ជនៈក្នុងភាសាបាលីដែលមានតែមួយពួក។ រីឯស្រៈក្នុងភាសាខ្មែរ មានពីរពួកខុសពីសូរស្រៈក្នុងភាសាបាលីដែលមានតែមួយពួក។

ក្នុងការធ្វើប្រភេទវិភាគស្រៈ ព្យញ្ជនៈ ព្យាង្គ ឱ្យមានគូគ្នាភាសាខ្មែរបានសំអាងទៅគោលពិសេសមួយចំនួនគឺ ខ្យល់ **អ-អ៊**។ ភាសាមនគេចែកជាខ្យល់ **អ-អេ** ឯភាសាបាលីសំស្ក្រឹតមានតែខ្យល់ **អៈ** (a) មួយទេ។ ចំពោះខ្យល់ **អ-អ៊** រួចមកហើយ មានអ្នកខ្លះយល់ច្រឡំថាព្យញ្ជនៈ

ណាដែលមានខ្យល់ **អ** ជាព្យញ្ជនៈ**អឃោសៈ** ឯព្យញ្ជនៈណាដែលមានខ្យល់ អ៊ ជាព្យញ្ជនៈ **ឃោសៈ។** ប៉ុន្តែតាមការពិសោធន៍ដោយគ្រឿងម៉ាស៊ីនថតសម្លេង គេបានដឹងថាព្យញ្ជនៈពួកខ្យល់ **អ** ក្តី ខ្យល់ **អ៊** ក្តីដែលមានសម្លេងមិនខ្ទរខ្ទារ(ថ្លង់) ហៅថាព្យញ្ជនៈ **អឃោសៈ។** ចំណែកព្យញ្ជនៈ**ឃោសៈ**វិញ គឺព្យញ្ជនៈពួកខ្យល់ **អ** ក្តី ពួកខ្យល់ **អ៊** ក្តីដែលមានសម្លេងខ្ទរខ្ទារ (លឺ)។ ព្យញ្ជនៈខ្យល់លឺមានចំនួនតិចណាស់ ៖ បប៊-ដឌ-ម៉ម-ណន-ញ៉ញ-ង៉ង-វ៉វ-ឡល-រ៉រ-យ៉យ។ ដូចនេះខ្យល់ពុំដូចខ្យល់**អឃោសៈ**ទេ ហើយខ្យល់ក៏ពុំដូចខ្យល់ឃោសៈដែរ។ ក្នុងការចែកមូលសទ្ទ (ស្រៈ-ព្យញ្ជនៈ-ព្យាង្គ) ខ្យល់ **អ-អ៊** បានវែកញែកមូលសទ្ទនោះជាគូៗគ្នាដូចជាៈ

- ស្រៈខ្យល់ អ ៖ ា ិ ី ឹ ឺ .....**ឧទាហរណ៍**៖ តា បី.....
- ស្រៈខ្យល់ អ៊ ៖ ា ិ ី ឹ ឺ.......**ឧទាហរណ៍**៖ ទា ពី....
- សញ្ញាស្រៈតែមួយបែប ប៉ុន្តែសម្គាល់ខ្យល់ អ ផង និង អ៊ ផង។
- ព្យញ្ជនៈខ្យល់អ ៖ ក ខ ច ឆ ដ.........
- ព្យញ្ជនៈខ្យល់ អ៊ ៖ គ ឃ ជ ឈ ឌ.....

**៤. ស្រៈអនុស័យ៖** ព្យញ្ជនៈនីមួយៗដែលយើងអាចបន្លឺបានអាស្រ័យដោយមានខ្យល់ អ ឬ អ៊ កប់នៅក្នុងព្យញ្ជនៈ នោះប៉ុន្តែស្រៈកប់ ឬ ស្រៈអនុស័យ នោះពុំឃើញរូបរាងទេ។ ក្នុងព្យញ្ជនៈ ក មានស្រៈកប់ "**អ**" ក្នុងព្យញ្ជនៈ ជ មាន ស្រៈកប់ "**អ៊**"។ ដោយសារមានស្រៈកប់នៅក្នុងនោះហើយបានជាព្យញ្ជនៈមួយតួអាចទៅជាព្យាង្គមួយមបានដូចជាៈ **ក**(កដៃ-កដប) **គ**(មនុស្សគ) **ត**(តជាប់គ្នា) ជាដើម។

ប៉ុន្តែគេអាចផ្តាច់ស្រៈកប់ចេញពីព្យញ្ជនៈ កាលណាព្យញ្ជនៈនោះមានមុខងារជាតួប្រកបដូចពាក្យ កាច គិត (ច និង ត គ្មានស្រៈកប់ទេមានតែខ្យល់ថ្ងប់)។

- ព្យាង្គខ្យល់ អ ៖ ក-កម-ចុក-ញាំ.....
- ព្យាង្គខ្យល់ អ៊ ៖ គ-គម-ជុក-ញាំ....

**៥. អំពីវិធីកម្លាយពាក្យ៖** ភាសាខ្មែរយើងមានវិធីកម្លាយពាក្យដើម ឬរឹស ឱ្យក្លាយជាពាក្យផ្សេងៗ ហើយមានន័យប្លែកៗគ្នា ប៉ុន្តែស្ថិតនៅក្នុងក្រុមញាតិតែមួយដោយប្រើផ្នត់ដើម និង

ផ្នត់ដែក។

**ឧទាហរណ៍៖**

- ផ្នត់ដើម ៖ ចូល > បញ្ចូល   កើត > បង្កើត....
- ផ្នត់ដែក ៖ លង > ល្បង   ជាន់ > ជ្ជាន់.....

ឯកីសដែលជាគុណនាម ក៏អាចរំលាយទៅជានាមបានដែរដូចជា៖ ធំ > ទំហំ ទាប > ទំនាប។ល។

ផ្នត់ដែកក្នុងភាសាខ្មែរប្លែកពីផ្នត់ដែកក្នុងភាសាបាលី-សំស្ក្រឹត ដែលគេហៅថាអាគម។ អាគមគ្រាន់តែចុះមកសម្រួលការភ្ជាប់សន្ធិឱ្យពិរោះតែប៉ុណ្ណោះ ពុំមែនចុះមកបំបែកឬសឱ្យមានន័យប្លែកគ្នាដូចផ្នត់ដែកក្នុងភាសាខ្មែរឡើយ។

**ឧទាហរណ៍៖**

- អ + អត្ត > អ + ន+ អត្ត > អនត្ត (ន=អាគម)
- ចតុ +អង្គ > ចតុ + រ + អង្គ > ចតុរង្គ (រ=អាគម)

ចំណែកផ្នត់ចុង ពុំឃើញមានប្រើក្នុងភាសាខ្មែរទេ ដែលមានលក្ខណះខុសពីភាសាបរទេស ជាពិសេសភាសាបារាំង និង អង់គ្លេស។

**៦. អំពីភេទ៖** ពាក្យនៅក្នុងភាសាខ្មែរយើងពុំមានភេទទេ ប៉ុន្តែមានពាក្យសម្រាប់សម្គាល់ភេទ។

**ឧទាហរណ៍៖**

- ភេទបុរស ៖ ប្រុស ឈ្មោល បា លោក អា.....
- ភេទស្រី ៖ ស្រី មេ អ្នកនាង ញី ..........

ចំណែកឯពាក្យនៅក្នុងភាសាបាលីសំស្ក្រឹត មានលក្ខណៈសម្គាល់ភេទរបស់វា។

**ឧទាហរណ៍ ៖**

- ភេទបុរស ៖ អ-ឥ-ឦ-ឧ-ឩ-។ ឧទាហរណ៍ ៖ មនុស្ស មនុ សេដ្ឋី គរុ.....។
- ភេទស្ត្រី ៖ អា-ឥ-ឦ-ឧ-ឩ-។ ឧទាហរណ៍ ៖ វាចា មតិ នារី ធាតុ វធូ.....។
- អភេទ ៖ អ-ឥ-ឧ-។ ឧទាហរណ៍: ផល អដ្ឋិ អាយុ....។

**៧. អំពីវចនៈ** ៖ ពាក្យនៅក្នុងភាសាខ្មែរយើងពុំមានវចនៈទេ ប៉ុន្តែមានពាក្យសម្រាប់សម្គាល់វចនៈរបស់ពាក្យ។

**ឧទាហរណ៍៖**

- ឯកវចនៈ ៖ មួយ ទោល ម្នាក់ ឯក....
- ពហុវចនៈ ៖ ពីរ បី.....ច្រើន ទាំងអស់ ទាំងស្រុង.....

រីឯពាក្យនៅក្នុងភាសាបាលីសំស្ក្រឹតវិញមានលក្ខណៈសម្រាប់សម្គាល់វចនៈរបស់វាជាស្រេច។

**ឧទាហរណ៍៖**

| **ឯកវចនៈ** | **ពហុវចនៈ** |
|---|---|
| កុមារ | កុមារា |
| បុរស | បុរិសា |
| រុក្ខ | រុក្ខា |
| មនុស្ស | មនុស្សា |
| យក្ស | យក្សា |

**៨. ថ្នាក់ពាក្យ**

- **នាប់៖** ខ្មែរយើងមានថ្នាក់ពាក្យមួយបែបគឺ"នាប់"។នាប់មានច្រើនយ៉ាងដូចជា៖
  - ក្បាល សម្រាប់ប្រើក្នុងការរាប់សត្វ សៀវភៅ ៖ គោប្រាំក្បាល សៀវភៅមួយក្បាល ។
  - នឹម សម្រាប់ប្រើក្នុងការរាប់សត្វសម្រាប់ទឹម ៖ គោមួយនឹម (មួយគូរពីរក្បាល) ក្របីពីរនឹម។
  - នាក់ សម្រាប់ប្រើក្នុងការរាប់មនុស្ស ៖ មនុស្សបីនាក់ សិស្សបួននាក់។
  - អង្គ សម្រាប់ប្រើក្នុងការរាប់ព្រះសង្ឃ ៖ ព្រះសង្ឃដប់អង្គ។
  - ចំរៀក សម្រាប់របាប់អ្វីៗដែលបានមកអំពីការច្រៀកះត្រីងៀតមួយចំរៀក។

- **គុណនាម៖** គុណនាមខ្មែរយើងអាចប្រើជាកិរិយាស្ទូលរបស់ល្បះបាន។ យើងហៅថា " គុណនាមកិរិយា " ៖

**ឧទាហរណ៍៖**

  - កុមារសុក**ឧស្សាហ៍** ណាស់។
  - កសិករភូមិយើង **ប៉ិនប្រសប់** ក្នុងការងារស្រែចំការ។

- **ជំនួយកិរិយា៖** ជំនួយកិរិយាមានច្រើនយ៉ាង តែជំនួយខាងស្តាំកិរិយាមានលក្ខណៈគួរអោយចាប់អារម្មណ៍៖

  - ជំនួយប្រាប់ទិសដៅ ៖ សុក ចេញ ***ទៅ*** ហើយ។
  - ជំនួយប្រាប់លទ្ធផល ៖ វា រក ***ឃើញ***។
  - ជំនួយប្រាប់លទ្ធភាព ៖ វា ដើរ ***កើត***។

**៩. អំពីសម្ព័ន្ធ៖** ពាក្យនៅក្នុងភាសាខ្មែរយើង ដែលគេយកទៅប្រើនៅក្នុងឃ្លាល្បះ ពុំមានការប្រែប្រួលរូបរាងរបស់ពាក្យនោះទេ។

**ឧទាហរណ៍៖**

- ខ្ញុំស្រលាញ់នាង ។
- នាងស្រលាញ់ខ្ញុំ ។

រីឯពាក្យកិរិយាក្តី នាមក្តី គុណនាមក្តី កាលណាមានទំនាក់ទំនងគ្នាក្នុងល្បះត្រូវតែមានការផ្លាស់ប្តូររូបរាងរបស់វាជានិច្ច។

**ឧទាហរណ៍៖**

- អហំ កាឡំ សុនខំ បស្សាមិ (ឯកវចនៈ)។
  ខ្ញុំ ខ្មៅ ឆ្កែ ឃើញ ។
- មយំ កាឡេ សុនខេ បស្សាម (ពហុវចនៈ)។
  យើង ខ្មៅ ឆ្កែច្រើន ឃើញ ។

គេឃើញមានប្រើភាសា ដែលគេអាចបង្កើតពាក្យថ្មីបាន ដោយប្រើបទដើម (prefixes) បទដែក(infixes) និងបទចុង(suffixes)។ ចំពោះខ្មែរយើងវិធីកម្លាយពាក្យដោយប្រើបទដើម និងបទដែកឃើញនៅស្ថិតស្ថេរហូតដល់សព្វថ្ងៃ ហើយប្រកបដោយក្បួនខ្នាតច្បាស់លាស់

ណាស់។ ម្យ៉ាងទៀត ការសិក្សាស្រាវជ្រាវបានបង្ហាញអោយឃើញថាវិធីបែបនេះ ក៏មានប្រើពិតប្រាកដក្នុងភាសាមនដែល ៖

| **ក្នុងភាសាខ្មែរ** | **ក្នុងភាសាមន** |
|---|---|
| ព + យល់ > ពន្យល់ | គេត (វិល) > បៈ គេត (បង្វិល) |
| ប + ដើរ > បណ្តើរ | គើ (ឆេះ) > ពគើ (បញ្ឆេះ) |
| គិត > គំនិត (គ + ន + ិត) | ក្លូន (ធ្វើការ) > កម្លូន (កិច្ចការ) |
| កាយ > កំណាយ (ក + ណ + ា យ) | ក្លូន (លួច) > កម្លូត (ចោរ) |

### ៣.២. អក្សរ

អក្សរគឺជាគំនូរសញ្ញាសំរាប់កត់ត្រាពាក្យសំដីរឿងព្រឹត្តិការណ៍ផ្សេងៗដែលតែងតែកើតឡើងនៅក្នុងសង្គមមនុស្ស។

#### ៣.២.១. ប្រវត្តនៃអក្សរ

ការសិក្សាស្រាវជ្រាវខាងប្រវត្តិអក្សរ បានឱ្យដឹងថា នៅប្រមាណ៥០០០ឆ្នាំមុន គ.ស ជនជាតិអេស៊ីបបានបង្កើតតួអក្សរជាលើកដំបូងមុនគេប៉ុន្តែគឺជាសញ្ញា រូបសត្វ រូបមនុស្ស រូបរុក្ខជាតិ រូបផ្កា រូបផ្កាយជាដើមដែលហៅថាសក្តិលេខ។









អក្សររូបបែបនេះពុំមានអ្នកណាអានរួចទេ។ ទើបតែនៅឆ្នាំ១៨២៤ ដល់១៨៥៤ លោក**សំប៉ូល្យុង** ចេះអានអក្សរជនជាតិអេស៊ីបនេះមុនគេ។



បន្ទាប់មក គេបានរកឃើញអត្ថបទសិលាចារឹកជាសក្តិលេខចិនមានអាយុប្រហែល ២០០០ឆ្នាំមុនគ.ស។

លុះក្រោយមកទៀត ប្រវត្តិវិទូបានស្រាវជ្រាវរកឃើញថា ជនជាតិហ្វេនីស៊ីជាអ្នកសាងតួអក្សរសំរេចឡើងជាដំបូងបង្អស់ ហើយអក្សរហ្វេនីស៊ីនេះ ក៏បានទៅជាដើមត្រកូលនៃអក្សររបស់ជនជាតិ ផ្សេងៗទៀតក្នុងអក្សរក្រិក-ឡាតាំង និងអក្សរព្រាហ្មី នៅប្រទេសឥណ្ឌា។

តាមការស្រាវជ្រាវរបស់លោកយូស៊ី មានអក្សរ២បែប បានកើតឡើងនៅប្រទេសឥណ្ឌា ប្រមាណជា១០០០ឆ្នាំមុន គ.សគឺអក្សរព្រាហ្មី និងខារោស្ត្រី។ បណ្តាអក្សរទាំងពីរបែបនេះបានផ្តល់ដើមកំនើតអក្សរឯទៀតជាច្រើននៅប្រទេសឥណ្ឌា។ ឯតួអក្សរព្រាហ្មីនោះកើតចេញមកអំពីអក្ខរក្រមបុរាណអំបូរសេមីត។ ក្នុងចំណោមអក្សរឥណ្ឌាជាច្រើន ដែលកើតចេញពីអក្សរព្រាហ្មី អក្សរទេវនាគរី ឬនាគរីត្រូវបានស្គាល់ជាងគេ ហើយដែលគេយកមកកត់ត្រាភាសាសំស្ក្រឹត។ លុះក្រោយមក អក្សរទេវនាគរីក៏បានក្លាយទៅជាអក្សរសំរាប់ជនជាតិឥណ្ឌាប្រើជាផ្លូវការរហូតមកដល់សព្វថ្ងៃ។ តើអក្សរ ខ្មែរមានដើមកំណើតមកពីអក្សរណាដែរ? នៅសម័យនគរភ្នំ(ហ្វូណន) គេបានរកឃើញសិលាចារឹកមួយនៅវ៉ូកាញ់ ក្នុងភូមិភាគញ៉ាត្រាង(យួនខាងត្បូង) ដែលគេបានចាត់ទុកថាជាសិលាចារឹកខ្មែរដំបូងបង្អស់ ប៉ុន្តែសេចក្តីក្នុងសិលាចារឹកនេះជាភាសាសំស្ក្រឹត។ តាមការសិក្សាប្រៀបធៀបអក្សរខ្មែរបុរាណនេះទៅអក្សរឥណ្ឌាប៉ែកខាងត្បូង គេបានរកឃើញទ្រង់ទ្រាយដូចគ្នា។ ម៉្យាងទៀត គេបានរកឃើញនៅអូកែវ (កំពង់ផែរបស់ខ្មែរនៅមាត់សមុទ្រកម្ពុជាក្រោម) នូវប្រាក់កាក់របស់ឥណ្ឌា ដែលនៅលើនោះគេចារអក្សរព្រាហ្មីមានទ្រង់ទ្រាយដូចតួអក្សរខ្មែរបុរាណដែរ។ ស្របតាមសម័យនោះខ្មែរ និងឥណ្ឌាមាន ទំនាក់ទំនងគ្នាញឹកញាប់ផង គេសន្និក៏ដ្ឋានថាខ្មែរបានខ្ចីយកតួអក្សរឥណ្ឌាព្រាហ្មមកប្រើ។

### ៣.២.២. ខវត្តន៍នៃអក្សរខ្មែរ

អក្សរដែលខ្មែរយកគំរូតាមអក្សរឥណ្ឌាខាងត្បូងមកប្រើប្រាស់ក្នុងសម័យនោះ ពុំដូចគ្នានឹងអក្សរសម័យបច្ចុប្បន្ននេះទេគឺ ត្រូវបានកែប្រែទ្រង់ទ្រាយចំនួន១០ដងរួចមកហើយ ទើបបានជារូបរាងពិតប្រាកដ ដូចជាតួអក្សរខ្មែរដែលយើងប្រើប្រាស់សព្វថ្ងៃ។ ដំណើរនៃការវិវត្តិព្យញ្ជនៈខ្មែរបុរាណមានចំនួនបីសម័យកាលដែលមានសណ្ឋានខុសគ្នាឆ្ងាយ ហើយកាន់តែឆ្ងាយណាស់ទៅទៀតនឹងតួព្យញ្ជនៈសម័យបច្ចុប្បន្ននេះ។

~ **ព្យញ្ជនៈសម័យមុនអង្គរ** ៖មានរាងគ្រោតគ្រាត មិនស្មើ មិនសម សក់ខ្លី ជើងខ្លី ហើយមានចំនួនតិច។



~ **ព្យញ្ជនៈសម័យអង្គរ ៖** មានរាងសង្ហា មានសក់ជាក្បាច់រចនា ជើងមានសឹងគ្រប់តួ។



~ **ព្យញ្ជនៈសម័យក្រោយអង្គរ ៖** មានរាងទ្រេត សក់ និង ជើងវែងៗ។



ដំណើរវិវត្តិមានច្រើនលើកច្រើនគ្រា តួអក្សររិតតែច្រើនឡើង រឹតតែងាយសរសេរឡើង ហើយរឹតតែល្អឡើងប្រកបដោយក្បូរក្បាច់យ៉ាងសមរម្យ។ នេះហើយជាស្នាដៃនៃបុព្វបុរសខ្មែរដែលមានទេពកោសល្យខាងកែសម្រួល និងខាងបង្កើតថ្មី ដើម្បីបំពេញនូវកង្វះខាតនេះឯង។ ក្រោយដែលមានកំណើតមាំមួនហើយ បន្ទាប់មកមានការវិវត្តពេញរូបរាងមែនទែនហើយ តើអក្សរខ្មែរមានលក្ខណៈពិសេសរបស់ខ្លួនយ៉ាងណាទៅដែរ?

### ៣.២.៣. លក្ខណៈពិសេសនៃអក្សរខ្មែរ

១. អក្សរពុំមែនជាសញ្ញាដាច់ដោយចេញពីគ្នា ដែលគេចេះតែយកមកកត់សម្គាល់សម្លេង ក្នុងភាសានីមួយៗនោះឡើយ ប៉ុន្តែអក្សរគឺជាកម្រងសញ្ញាដែលទាក់ទងគ្នាជាក្បួននៃតួសញ្ញាដែលទាក់ទងគ្នាទៅលើមូលវិធី (principle) ដ៏សំខាន់។

២. នៅក្នុងអក្សរខ្មែរគេនិយមភ្ជាប់ស្រៈ និងព្យញ្ជនៈឱ្យជាប់គ្នា ដែលជាហេតុនាំឱ្យមានទំនាក់ទំនងទៅវិញទៅមករវាងស្រៈ និងព្យញ្ជនៈ។ ទំនាក់ទំនងនេះបណ្ដាលអោយកើតមានស្រៈកប់ ឬស្រៈអនុស័យក្នុងព្យញ្ជនៈនេះឯង។ ដូចយើងបានពោលក្នុងផ្នែកភាសារួចមកហើយថា ស្រៈកប់ខ្មែរមានពីរប្រភេទគឺ អ-អ៊។ ឯស្រៈកប់បាលីមានតែមួយគឺ អៈ(a)។ ដោយមានស្រៈអនុស័យពីរបែបកប់នៅក្នុងព្យញ្ជនៈ ហើយនាំឱ្យមានព្យញ្ជនៈអនុស័យ ២បែបដែរ គឺព្យញ្ជនៈអនុស័យពួក អ ដូចជា ក ខ ច ឆ ដ ឋ......... និងព្យញ្ជនៈអនុស័យពួកអ៊ ដូចជា គ ឃ ឈ ទ ធ.....។ ចំណែកស្រៈនិស័យមាន ដូចជ ា ិ ី ឹ ឺ ុ ូ ក៏ចែកជាពីរប្រភេទស្របទៅនឹងព្យញ្ជនៈអនុស័យពួកអ និងពួកអ៊ ដូចនេះទៀត ប៉ុន្តែមានសញ្ញាសម្គាល់តែមួយ បែប(ឧ.សញ្ញាសម្គាល់អា ផង អ៊ា ផង)។

៣. អាស្រ័យដោយមានស្រៈអនុស័យក្នុងព្យញ្ជនៈបែបខាងលើនេះហើយទើបព្យញ្ជនៈអនុស័យមួយតួៗអាចទៅជា ព្យាង្គមួយបាន។ ឧទាហរណ៍ ៖ត (តទល់) ខ (ខត្រី) ស (ពណ៌ស) គ (មនុស្សគ)។ លក្ខណៈពិសេសនេះខុសប្លែកអំពី អក្សររ៉ូម៉ាំង (Romain) មានអក្សរបារាំងជាដើម ដែលព្យញ្ជនៈមួយតួពុំអាចទៅព្យាង្គមួយបានទេ ដូចជាព្យញ្ជនៈ b-k-p-l-m ជាដើម។

៤. ក្នុងអក្សរខ្មែរ ព្យញ្ជនៈ២តួនៅរៀងគ្នា ក៏អាចទៅជាព្យាង្គមួយបានដែរ ដូចជាពាក្យ ៖ មក បង (តួ ម និង តួ បជា ព្យញ្ជនៈដើមព្យាង្គ(consonant initial) ឯតួ ក និងតួ ង ជាព្យញ្ជនៈប្រកប (consonant female))។ ព្យញ្ជនៈដែលមាន មុខងារជាខ្យល់ប្រកបពុំមានស្រៈអនុស័យឡើយ គឺមានតែខ្យល់ព្យញ្ជនៈតែប៉ុណ្ណោះ។ ពិតមែនតែពុំមានសញ្ញាសំគាល់ថាពុំ មានស្រៈអនុស័យក្នុងព្យញ្ជនៈប្រកបដូចនេះក៏ដោយ ក៏ខ្មែរយើងពុំអាចច្រឡំបានទេ ព្រោះគេអាចដឹងបានដោយន័យរបស់ពាក្យនោះ **ឧទាហរណ៍៖** ទូកងលើកដាក់លើក ពានាស។ ចំណែកនៅក្នុងអក្សររ៉ូម៉ាំង ដែលនិយមផ្ដាច់ស្រៈចេញអំពីព្យញ្ជនៈ ហើយពុំនិយមប្រើស្រៈអនុស័យព្យញ្ជនៈអនុស័យដូចខ្មែរនោះ ព្យញ្ជនៈ២ ឬ៣តួនៅជិតគ្នាពុំអាចទៅព្យាង្គបានទេ ប៉ុន្តែជាព្យញ្ជនៈសំយោគ(ព្យញ្ជនៈផ្សំ) (group consonant antique) ទៅវិញ **ឧទាហរណ៍៖** tr (trouver), spl (splendeur) ។

៥. រីឯ ព្យញ្ជនៈសំយោគខ្មែរ ពុំសរសេរតួពញ្ជនៈរៀងគ្នាដូចនេះទេ គឺសរសេរត្រួតព្យញ្ជនៈលើគ្នាទៅវិញ ជាបុព្វហេតុមួយយ៉ាងសំខាន់បណ្ដាលឱ្យមានការបង្កើតជាជើងរបស់ព្យញ្ជនៈឡើយ។ ដូចនេះហើយបានជាយើងថា ព្យញ្ជនៈនីមួយៗនៅសម័យបច្ចុប្បន្នសុទ្ធតែមានជើង។ ការបង្កើតជើងនៃព្យញ្ជនៈនេះគឺដើម្បីយកទៅសរសេរ ផ្ញើរក្រោមព្យញ្ជនៈមួយទៀតឱ្យ

មានសភាពត្រួតគ្នាផ្សំសម្លេងគ្នាជាព្យញ្ជនៈសំយោគ គឺព្យញ្ជនៈផ្សំនេះឯង។ **ឧទាហរណ៍៖** ខ្យ (ខ្យល់) ខ្ល (ខ្លី) ក្រ........

**៦.** ក្រៅពីនេះ ជើងនៃព្យញ្ជនៈសម្រាប់ប្រើជាព្យញ្ជនៈដើមព្យាង្គនៃព្យាង្គតំរួតថែមទៀត។ **ឧទាហរណ៍៖** ពន្យល់=ពន់ (ព្យាង្គទី១)+ យល់ (ព្យាង្គទី២)។ ជើង"្យ" ក្នុងពាក្យ"ខ្យល់" និង ជើង "្យ"ក្នុងពាក្យ "ពន្យល់" ពិតមែនតែមានរូបរាងដូចគ្នាក៏ដោយ ក៏ពុំមានមុខងារដូចគ្នាទេ។ ក្នុងព្យញ្ជនៈ សំយោគជើងព្យញ្ជនៈគឺ ខ្យល់ផ្សំជាមួយ ព្យញ្ជនៈត្រួតលើ។ ចំនែកជើងព្យញ្ជនៈក្នុងព្យាង្គតំរួតវិញពុំមែនជាសម្លេងផ្សំទេ គឺជាព្យញ្ជនៈដើមព្យាង្គនៃព្យាង្គតំរួតនេះឯង យើងបានឃើញថា វិធីផ្ញើជើងនេះជាមែកធាងបែកចេញអំពីមូលវិធីអនុស័យស្រៈ-ព្យញ្ជនៈ (Principle des voyelles et consonnes inhérentes) ហើយវិធីផ្ញើជើងនេះ មានផលវិបាក (consequence) សំខាន់ៗដែលប្រព្រឹត្តទៅនៅលើក្បួនវិធីច្បាស់លាស់ណាស់។ ដោយក្បួនវិធីទាំងនោះវែងឆ្ងាយពេក យើងសូមមិនលើកយកមកអធិប្បាយក្នុងពេលនេះទេ។

**៧.** ពញ្ជនៈសំយោគនៅក្នុងភាសាខ្មែរយើង ក៏អាចជាពាក្យមួយដែរ។ **ឧទាហរណ៍៖** ក្រ (សិស្សក្រ) ទ្រ (ទ្រខ្មែរ) ហ្ម (ដំរី)។

**៨.** លក្ខណៈពិសេសមួយទៀតរបស់អក្សរខ្មែរយើង គឺព្យញ្ជនៈមានសក់។ តើសក់នោះមានប្រយោជន៍យ៉ាងណាដែរ?

រួចមកហើយយើងបានឃើញគេយកសក់" ៊"(អ្នកខ្លះហៅសក់ "ក") ដែលមានសណ្ឋានដូចជាលេខ៣ ហើយដែលបាលី ហៅថាត្រីស័ព្ទមកប្រើដាក់លើព្យញ្ជនៈពួក "អ"៖ ប ស ហ ឱ្យទោជាពញ្ជនៈពួក"អ៊"៖ ប៊ ស៊ ហ៊ វិញ។ សក់របស់ព្យញ្ជនៈឯទៀត ពុំឃើញយកមកប្រើផងទេ។ យើងថាការធ្វើឱ្យព្យញ្ជនៈមានសក់ពុំមែន ជាការឥតប្រយោជន៍នោះឡើយ ផ្ទុយទៅវិញសក់ព្យញ្ជនៈ គឺជាក្បាច់ដែលបុព្វបុរសយើងបានរចនាឡើង ដើម្បីលំអព្យញ្ជនៈនីមួយៗឱ្យមានសភាពសមសួនឡើង។ ចំណែកអក្សរ សៀម លាវ ដែលយកលំនាំអក្សរ តាមខ្មែរយើង ហើយយកទៅកែប្រែលុបសក់ចេញ មើលទៅហាក់ដូចជា មនុស្សដែលមានក្បាល ប៉ុន្តែអត់សក់ដូចនោះដែរ។ ក្រោយពីបានសិក្សាអំពីប្រភពវិវត្តន៍ និងលក្ខណៈពិសេសនៃអក្សរខ្មែរ មកយើងបានឃើញថាខ្មែរបានយកលំនាំ តាមអក្សរឥណ្ឌាមកប្រើប្រាស់ជាលើកដំបូងក៏ពិតមែន ក៏ប៉ុន្តែបន្ទាប់មកខ្មែរមានទេពកោសល្យខាងច្នៃឱ្យបានសមសួន ខាងបង្កើតថ្មីឱ្យសំបូរគ្រប់គ្រាន់ព្រមទាំងមានក្បួន

ខ្វាតមានវិធីច្បាស់លាស់ សម្រាប់ ជនជាតិខ្មែរយកទៅប្រើការបាន យ៉ាងងាយក្នុងការកត់ត្រា គំនិត សញ្ចេតនា ព្រឹត្តិការណ៍ ប្រវត្តិសាស្រ្ត។ល។

## ៤. ស្ថានីយ៍បុរេប្រវត្ត

### ៤.១. ស្ថានីយព្រែកឆ្លូង

នេះជាស្ថានីយថ្មរំលីងមួយដែលលោក**B.P.Grosiler** បានរកឃើញនៅព្រែកឆ្លូង(ស្រុកមេមត់ខេត្តកំពង់ចាម)នៅឆ្នាំ១៩៦៣(10)។ ជាយូរហើយ លោកGroslier បានសិក្សាពីលើយន្តហោះនូវស្នាដៃធ្វើពីដីមានរាងមូល ដែលនៅរាយប៉ាយ ចាប់តាំងពីឡាបាសៀក ដល់ឡុកនិញ (LoxNinh) ក្នុងប្រទេសវៀតណាមខាងត្បូងដោយឆ្លងកាត់តាមមេមត់ បានសេចក្តីថា ស្នាដៃទាំងនោះស្ថិតនៅក្នុងតំបន់ដីក្រហមនៃចំការកៅស៊ូធំៗ។ មានសញ្ញា និងសម្មតិកម្មជាច្រើនបានស្របគ្នា ជាហេតុនាំអោយលោកGroslier ជឿថាទីកន្លែងទាំងនោះ ជាទីលំនៅរបស់ជនជាតិខ្មែរជាដើម។ ដូច្នេះដើម្បីធ្វើការ បញ្ជាក់ពីគំនិតនេះនៅឆ្នាំ១៩៦២លោកGroslier បានជ្រើសរើសយកទីកន្លែងមួយនៅព្រែកឆ្លូងដើម្បីធ្វើកំណាយ ព្រោះកន្លែងនោះស្ថិតនៅចំកណ្តាលប្រពន្ធ័ទាំងមូល។ ក្នុងការរុករកនេះលោក Groslier បានរកឃើញរបស់ធ្វើពីថ្ម និងគ្រឿងចាន ឆ្នាំងមួយចំនួនធំ។ វត្ថុទាំងនោះ បានបង្ហាញអោយឃើញថា នៅត្រង់កន្លែងដែលជាជំរំការពារយ៉ាងមាំមួននោះមានមនុស្សរស់នៅដោយមានការរៀបចំយ៉ាងហ្មត់ចត់ហើយ។ ជុំរំដែលលោកGroslierបានសិក្សាមានកំពែងរាងមូលព័ទ្ធជុំវិញ(វិជ្ជមាត្រជាង២០០ម.) ហើយមានផ្លូវចូលពីរ។ អាយុនៃជំរំមានប្រហែលពី១៥០០ដល់៥០០ឆ្នាំមុនគ.ស។ ប្រដាប់ប្រដាដែលធ្វើពីថ្មរលីង មានរាងប្លែកៗខ្លះមានរាងជាពង ខ្លះមានរាងជាចតុមុខយកលំនាំតាមរបស់ដែលធ្វើពីលង្ហិនដំបូង។ គ្រឿងចាន ឆ្នាំងមានរាងច្រើនបែបយ៉ាង ហើយមានក្បាច់រចនាល្អវិចិត្រ ប៉ុន្តែក្រោយមកបែរជាមានសភាពគ្រោតគ្រាតគ្មានលំអអ្វីសោះ។ វត្ថុទាំងអស់នេះគេចាត់ទុកថាជាស្នាដៃរបស់ជនជាតិខ្មែរដើមមុនពេលដែលជនជាតិនេះចុះមករស់នៅត្រង់វាលទំនាបនៃទន្លេមេគង្គ និងមុនពេលដែលបានទទួលអរិយធម៌ឥណ្ឌា។

### ៤.២. ស្ថានីយល្អាងស្ពាន

ពីឆ្នាំ១៩៦៦ដល់១៩៦៩ លោក និងលោកស្រី**Mourer** សាស្រ្តាចារ្យនៅមហាវិទ្យាល័យបុរាណវត្ថុវិទ្យា ដោយមាននិស្សិតនៃមហាវិទ្យាល័យនេះចូលរួមផង បានធ្វើកំណាយនៅរូងភ្នំល្អាងស្ពាននៃភ្នំទាកទ្រាំង មានចម្ងាយប្រមាណ៥គ.មពីអណ្តើកហែបខេត្តបាត់ដំបង។ វត្ថុដែល

គេបានរកឃើញមានចំនួនប្រមាណជា២០០០ ហើយមានជាអាទិ៍គ្រឿងប្រដាប់ធ្វើពីថ្មសំណល់ផ្ទះបាយសាកសពសត្វល្អិតចំណែកគ្រឿងចាន ឆ្នាំង ឆ្អឹងសត្វ(Rhino cerosSondaicusmDesm) និងឆ្អឹងមនុស្ស(ឆ្អឹងដើមដៃនិងឆ្អឹងដងកាំបិត)។ វត្ថុទាំងនេះត្រូវបានគេផ្ញើទៅប្រទេសបារាំងដើម្បីធ្វើការសិក្សា។ ដុំធ្យូងជាច្រើន ដែលគេឃើញក្នុងស្រទាប់លើអនុញ្ញាតអោយគេចុះកាលកំណត់ដោយវិធីវិទ្យុសកម្ម ៖

- ស្រទាប់ទី១ ៖១២០០BP(750 ក្រោយគ.ស)
- ស្រទាប់ទី៣ ៖៤២០០BP(2050 មុនគ.ស)
- ស្រទាប់ទី៤ ៖៦២៥០BP(4290 មុនគ.ស)

### ៤.៣. ស្ថានីយភ្នំក្បាលរមាស

នៅចន្លោះឆ្នាំ១៩៦៦ និង១៩៦៩ លោក**Carbonnel** និង**Dalibrias** បានធ្វើការរុករកក្នុងរូងភ្នំ ដែលជាលំនៅរបស់មនុស្សបុព្វប្រវត្តិសាស្ត្រនៅភ្នំក្បាលរមាសក្នុងខេត្តកំពត។ នៅទីនោះលោកទាំងពីរបានរកឃើញនូវគ្រឿងចានឆ្នាំង ដែលមានអាយុ៣៩២០ ឆ្នាំមុនគ.ស។

### ៤.៤. ស្ថានីយ៍សំរោងសែន-អន្លង់ផ្តៅ-ម្លូព្រៃ

សំរោងសែនជាស្ថានីយ៍មួយ ស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង ខាងជើងបឹងទន្លេសាប។ ស្ថានីយ៍នេះជាដីទួលមួយ មានកំពស់៥ម៉ែត្រ ហើយមានផ្ទៃប្រមាណជា៦០០០ម៉ែត្រក្រឡាប៉ុណ្ណោះ។ លោក **Roques** បានរកឃើញស្ថានីយ៍នេះនៅឆ្នាំ ១៨៧៦ ឯលោក **Corre** បានបោះពុម្ពផ្សាយពីរបស់ដែលគេបានរកឃើញនៅទីនោះនៅឆ្នាំ១៨៧៩។ ក្រោយមកលោក **Moura**លោក **Aymonier** (១៩០១) លោក **Mansuy**(១៩០២) និង(១៩២៣)បានទៅធ្វើការរុករកនៅទីនោះទៀត។ ការរកឃើញស្ថានីយ៍នេះនៅឆ្នាំ១៨៧៦ ជាជំហានដំបូងក្នុងការស្រាវជ្រាវផ្នែកបុព្វប្រវត្តិសាស្ត្រនៅអាស៊ីអាគ្នេយ៍។ អន្លង់ផ្តៅជាស្ថានីយ៍មួយស្ថិតនៅចម្ងាយ៣០គ.មត្រង់ទិសអាគ្នេយ៍ ពីសំរោងសែន ហើយមានប្រដាប់ប្រដាដូចនៅស្ថានីយ៍ខាងលើនេះដែរ លោក **Mansuy** បានរកឃើញស្ថានីយ៍នេះនៅឆ្នាំ១៩០២ ហើយបានដាក់ឈ្មោះហៅថា**Long Prao**ទៀតផង។ ម្លូព្រៃស្ថិតនៅខាងជើងខេត្តព្រះវិហារ ហើយត្រូវបានរកឃើញដោយលោក **P.Levy** នៅឆ្នាំ១៩៤៣។ ស្ថានីយ៍នេះថ្មីជាងស្ថានីយ៍ពីរខាងលើ ព្រោះមានប្រដាប់ប្រដាធ្វើពីលោហៈធាតុច្រើន។ វត្ថុដែលគេបានរកឃើញនៅស្ថានីយ៍ទាំងបីនេះមានៈ

~ **ពីថ្មរំលីង** ៖ ពូថៅដែលមានពន្លូញពន្លាក ញញួរត្បោង ដុំសំបកឈើយកសរសៃទ្រនាប់ កាំបិត កណ្តៀវថ្មសំ លៀងពុម្ពចាក់កណ្តៀវកងដៃក្បាលត្រល់អង្រៃផ្លែសន្ទូច។

~ **ពីឆ្អឹងសត្វ** ៖ ចុងព្រួញ កាំបិត ផ្លែសន្ទូច កណ្តៀវ គ្រឿងអលង្ការ។

~ **ពីសំបកខ្យង** ៖ ទំហូអង្កាំ ក្អម ឆ្នាំង ចានទាប ចានក្រឡូម ចានជើង។

~ **ពីលង្ហិន** ៖ ចុងព្រួញ កណ្តៀវ ពូថៅ ជួង ផ្លែសន្ទូច។

~ **ពីដែក** ៖ មានតែពន្លាក១គត់នៅស្ថានីយ៍ម្លូព្រៃ។

~ **ឆ្អឹងមនុស្ស** ៖ ឆ្អឹងស្មង ឆ្អឹងភ្លៅ ឆ្អឹងដើមដៃ លលាដ៍ក្បាល១។

~ **សំណល់** ៖ ផ្ទះបាយធ្យូង។

ក្នុងចំណោមរបស់ទាំងឡាយដែលបានរៀបរាប់ពីខាងលើ យើងបានសង្កេតឃើញថា វត្ថុធ្វើពីថ្មរំលីងបាននៅលាយឡំជាមួយ នឹងវត្ថុធ្វើពីលោហះធាតុ។ ដូច្នេះយើងអាចសន្និដ្ឋានបានថា នៅប្រទេសខ្មែរយើងពុំមានព្រំដែនអោយច្បាស់លាស់រវាងយុគថ្ម និងយុគលោហៈទេ។ ឯរបស់ដែលធ្វើពីដែកមានតែ១គត់ គឺពន្លានៅម្លូព្រៃត្រង់នេះសឲ្យឃើញថាមនុស្សបុព្វប្រវត្តិសាស្រ្តប្រហែលជាមិនទាន់ចេះស្លដែកនៅឡើយទេ ហើយក៏បានរៀនបច្ចេកទេសនេះពីឥណ្ឌា ព្រោះគេបានសង្កេតឃើញថា ពួកកួយដែលចេះស្លដែកនៅក្នុងខេត្តកំពង់ធំ នៅប្រើប្រាស់ស្នប់ដែលគេឃើញមានប្រើក្នុងរដ្ឋឧរិស្សរបស់ឥណ្ឌានៅឡើយ។ ម្យ៉ាងទៀត ពិធីសែនព្រេនដែលពួកកួយប្រារព្ធធ្វើមុនពេលស្លដែកម្តងៗក៏ជាពិធីខាងសាសនាព្រាហ្មណ៍។

គួរបញ្ជាក់ថានៅឆ្នាំ១៩០១ គេបានរកឃើញនៅកោះសំរោងសែននូវលលាដ៍ក្បាល១ ដែលពុកផុយច្រើនណាស់ទៅហើយដោយសារតែទឹកជំនន់នៅទីនោះ។ ក្រោយពីបានសិក្សា ពួកបុព្វប្រវត្តិវិទូ បានចាត់ទុកថាឆ្អឹងលលាដ៍នេះស្ថិតនៅ ចន្លោះពួកក្បាលកណ្តាល(mesocephalie) និងពួកក្បាលមូល។ បើដូច្នេះយើងឃើញថាចំណាត់ខាងលើនេះ មានលក្ខណៈស្របនឹងលទ្ធផលរបស់លោកដែលលោកបានរកឃើញថាជនជាតិខ្មែរបច្ចុប្បន្ននេះ ជាពូជដែលមានក្បាលមូល ដោយមានសន្ទស្សន៍លលាដ៍៨៣,៦។ ការប្រៀបធៀបនេះអនុញ្ញាតអោយយើងសន្និដ្ឋានបានថា មនុស្សដែលបានរស់នៅសម័យសំរោង សែនគឺពិតជាបុព្វបុរសរបស់ជនជាតិខ្មែរសព្វថ្ងៃហើយ លោកមិនទាន់បានទទួលឥទ្ធិពលឥណ្ឌានៅឡើយក្នុងវិស័យបូជាសព។ ដោយសំអាងទៅលើកំពស់ដីល្បាប់(៥ម) ដែលគ្របពីលើស្ថានីយ៍សំរោងសែន អ្នកបច្ចេកទេសបានសន្និដ្ឋានថា ស្ថានីយ៍នេះ មានអាយុប្រហែលជា១០០ ឬ២០០ឆ្នាំមុនគ.ស។

## ៥. កត្តាជីវសាស្ត្រ

ភាសាវិទូជនជាតិអាល្លឺម៉ង់ **P.W. Schmidt** បាននិយាយថាអំបូរ ខ្មែរ-មន មិនគ្រាន់តែជាអំបូរភាសាទេ តែជាអំបូរជាតិសាសន៍ផងដែរ។ក្នុងសៀវភៅ Lespeuples mon-Khmer បោះពុម្ពផ្សាយនៅឆ្នាំ១៩០៨ នៅហាណូយ លោកបានបង្ហាញនូវលក្ខណៈរូបរាងកាយរបស់ជនជាតិទាំងនោះដែលមានដូចតទៅ:

~ មាឌតូចល្មម អាចឡើងដល់មធ្យម
~ ស្បែកសម្បុរស្ដែកបាយ
~ ភ្នែកមានសណ្ឋានត្រង់ ហើយផ្ដេក បើកធំៗ
~ ច្រមុះទូលាយ
~ ក្បាលពយ

គួរកត់សម្គាល់ថា ចំពោះមាឌក្ដី លលាដ៍ក្បាលក្ដីលោក **P.W. Schmidt** ពុំបានបង្ហាញលេខក្នុងការវាស់វែងឲ្យបានច្បាស់លាស់ទេ ហើយមានចំណុចខ្លះដូចជាលលាដ៍ក្បាលជាដើម លោកបានបង្ហាញលទ្ធផលដែលមានទំនាស់នឹងលទ្ធផលផ្ដល់ដោយអ្នកប្រាជ្ញផ្សេងទៀត។ក្នុងសៀវភៅមានចំណងជើងថា Les populations du Cambodge លោក បណ្ឌិត **G.Olivier** និងលទ្ធផលនៃការស្រាវជ្រាវរបស់លោក **Henri Vallois** នរវិទូក្នុងពិភពលោក មកពិនិត្យមើលឃើញថា មនុស្សខ្មែរ និងមនុស្សឥណ្ឌា(ទាំងពួកស ទាំងពួកខ្មៅ) មានលក្ខណៈរូបរាងកាយខុសគ្នាឆ្ងាយណាស់។ ដោយលទ្ធផលនៃការស្រាវជ្រាវបង្ហាញ ឱ្យឃើញមានដូចខាងក្រោម:

~ ខ្មែរមានកំពស់ជាមធ្យម ១.៦១ម និងសន្ទស្សន៍លលាដ៍ក្បាល ៨៤.៥ មានក្បាលមូល
~ មនមានកំពស់ជាមធ្យម ១.៦២ម និងសន្ទស្សន៍លលាដ៍ក្បាល ៨៥.៦ មានក្បាលមូល
~ ពួកឥណ្ឌាស(អារ្យ) មានកំពស់មធ្យម១.៧២ម និងសន្ទស្សន៍លលាដ៍ក្បាល៧៣.៨ម មានក្បាលពយ
~ ពួកឥណ្ឌាខ្មៅ(ទ្រាវិឌ) មានកំពស់មធ្យម ១.៦២ម សន្ទស្សន៍លលាដ៍ក្បាល ៧៦.២ មានក្បាលពយ
~ ពួកមេឡានេស៊ីយាង មានកំពស់មធ្យម ១.៦៥ម មានក្បាលពយ
~ ពួកឥណ្ឌូនេស៊ីយាង មានកំពស់ចាប់ពី ១.៦០ម-១.៦៣ម មានក្បាលមូល

បើយោងតាមលទ្ធផលខាងលើនេះយើងឃើញថា ខ្មែរ និងមនមានកំពស់មធ្យមដូចគ្នា (ខុសគ្នាតែ១ភាគរយ តែប៉ុណ្ណោះ) ឯក្បាលក៏មូលដូចគ្នាទៀត (ខុសគ្នាតែ១.១) មិនមែនពយដូច លោក P.W. Schmidt យល់នោះទេ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏យើងអាចយល់ថាត្រង់ហ្នឹងគ្រាន់តែជាការភ័ន្តច្រឡំទេព្រោះលោកបានសរសេរសន្និដ្ឋានថា លក្ខណៈទាំងនោះអនុញ្ញាតឲ្យលោកអះអាងថា ពួកមនុស្សនោះស្ថិតដាច់ចេញពីអំបូរម៉ុងហ្គោលផង និងអំបូរ អារ្យផង។

ក្នុងនោះទៀតសោត ក្រុមអ្នកស្រាវបានស្រាវជ្រាវ ក៏ដូចជាបានពិនិត្យទៅលើប្រភេទឈាមអំបូរមនុស្សដែលស្ថិតនៅក្នុងអំបូរខ្មែរមនទៅឃើញថា សុទ្ធតែមានប្រភេទឈាមអេម៉ូក្លូប៊ីន E ដូចគ្នា ។

## ៦. ប្រភពរឿងព្រេង

### អភិសេកព្រះថោងនាងនាគ

ថ្ងៃមួយព្រះថោងបាននាំសេនាពលរេហ៍ទៅក្រសាលតាមឆ្នេរក្សាច់កោះ បានយាងទៅដល់ទួលដំបូកគោកធ្លក។ ដោយហេវហត់អស់កម្លាំងខ្លះ ព្រះអង្គបានចូលទៅសម្រាកក្រោមដើមធ្លក។ ដល់ពេលរសៀលទើបព្រះអង្គភ្ញាក់។តែទឹកបានឡើងលេចព័ទ្ធព័ន្ធជិតជុំវិញទួលគោកធ្លក។ ដោយមិនអាចត្រឡប់ទៅវាំងប្រាសាទវិញបាន ព្រះថោងទ្រង់ក៏គង់សម្រាកនៅទីនោះរង់ចាំដល់ពេលទឹកស្រកដកទៅវិញ។ នៅគ្រានោះនារាត្រីដ៏សែនស្ងាត់ជ្រងំ ព្រះនាងធារាវត្តី បុត្រីស្តេចភុជង្គនាគ បាននាំអស់ពពួកភាលៀងបរិវារចេញមកក្រសាលលេងកំសាន្តទឹកលើកោះគោកធ្លក។ ព្រះថោងទតឃើញព្រះនាងកាលណា ក៏លបលួចចាប់ចិត្តប្រតិព័ទ្ធស្នេហាភ្លាម។ ក្រោយដែលបានផ្តោះផ្តងសាកសួរជាមួយគ្នាទៅវិញទៅមកព្រះថោង និងនាងនាគក៏ចាប់ផ្តើមមានចិត្តស្នេហាស្មោះស្ម័គ្រនឹងគ្នាទៅវិញទៅមក។ ក្នុងរវាងប្រាំថ្ងៃតាមពេលកំណត់រវាងគូស្នេហ៍ទាំងពីរព្រះថោងត្រូវរៀបចំជំនូន និងអណ្តាប់ បណ្ណាការ គ្រប់បែបយ៉ាងមករង់ចាំនៅត្រង់ទីកន្លែងដដែល។ ចំណែកឯ ព្រះនាងធារាវត្តីកាលបើទៅដល់ឋានភុជង្គនាគ ក៏បានរ៉ាយរាប់រឿងរ៉ាវទាំងប៉ុន្មានតាមដំណើរទូលថ្វាយដល់ព្រះបិតា និងព្រះមាតា។ ស្តេចភុជង្គនាគមិនបានយល់ជំទាស់ទេ។ ព្រះអង្គបានសុខចិត្ត និងយល់ព្រមទៅតាមសំណូមពរគោលបំណងរបស់កូន។ ប្រាំពីរថ្ងៃកន្លងមកព្រះថោង បាននាំពលរេហ៍សេនា លើកជំនូនសួយសារអាករគ្រប់បែបយ៉ាងរៀបចំដោយប្រណិតយ៉ាងបរិបូរណ៍ឥតមានខ្ចោះត្រង់ណា យកមកទុកត្រៀមខ្លួន រង់ចាំនៅត្រង់ដើមធ្លក។

ដល់ថ្ងៃកំណត់ ស្តេចភុជង្គនាគ និងព្រះអគ្គមហេសីបានយាងចេញមកត្រង់កន្លែងដើមថ្លុកមែន។ បានយល់បានឃើញព្រះមាតា ព្រះបិតាព្រះនាងធារាវត្តីភ្លាមកាលណា ព្រះថោងលត់ជង្គង់ក្រាបថ្វាយបង្គំដោយក្តីគោរព។ ស្តេចភុជង្គនាគ និងមហេសីពេញចិត្តត្រេកអរសាទរណាស់ បានទទួលព្រះថោងជាកូនប្រសា ហើយក៏បានរៀបចំអភិសេកកូនស្រីកូន ប្រុសជាគូស្វាមីភរិយាតរៀងមក ស្តេចភុជង្គនាគព្រមទាំងបរិវារ ដើម្បីទុកជាចំណងដៃដល់កូនប្រុសស្រី បាននាំពលរេហ៍សេនាបឺតពង្រីងទឹកសមុទ្រ បង្កបង្កើតបានជាដីស្ងួតធំធេងទូលំទូលាយ ហើយបានកសាងប្រាង្គប្រាសាទរាំងតូចធំទុកថ្វាយជា ច្រើន។

ព្រះថោងនាងនាគត្រូវបានរៀបចំអភិសេក ជាគូស្វាមីភរិយា នៅវេលាម៉ោង៧ព្រឹក នៅថ្ងៃ ១១កើត ខែពិសាខ ព.ស.២៧៧ឆ្នាំម្សាញ់ ត្រូវជាឆ្នាំ២៦៧មុនគ.ស។ កាលនោះព្រះថោងបានព្រះជន្ម៩៦វស្សា។ ក្នុងពេលជាមួយគ្នានេះដែរ ព្រះថោងក៏បានទទួលព្រះរាជាភិសេកឡើងសោយរាជ្យសម្បត្តិនគរគោកធ្លកដែរ។ ព្រះអង្គបានទទួលគោរម្យនាម "ជាព្រះបាទសម្តេចកុម៉ៃរាជសេដ្ឋាធម្មិក វរោត្តមបឋមខេមរា ខត្តិយាវង្សសកូល កំពូលក្រុងកម្ពុជាធិបតីសិរីយសសោភាបវររាជធានីបូណ៌មី ឧត្តមមហាដ្ឋាន"។ ព្រះអគ្គមហេសី នាងនាគ ឬព្រះនាងធារាវត្តី បានទទួលព្រះនាមជា"សម្តេចព្រះវគត្តី ក្សត្រីគាប់លក្ខណ៍ឯកអគ្គទេវី"។ ពិធីបុណ្យអភិសេក ចប់សព្វគ្រប់កាលណាស្តេចភុជង្គនាគ និងព្រះអគ្គមហេសីបាននាំបរិវារនាម៉ឺនមុខមន្ត្រី ត្រឡប់ចុះទៅព្រះនគរវិញ។ ដើម្បីជូនដំណើរព្រះបិតាព្រះមាតាក្មេកចុះទៅឋានភុជង្គនាគ ព្រះថោង ឬព្រះបាទសម្តេចកុម៉ៃរាជ បានចាប់តោងស្បៃនាងនាគចុះតាមទៅជាមួយដែរ។ កាលនោះព្រះថោងបានរៀបចំសាងសង់ព្រះបរមរាជវាំងគង់នៅមហានគរធំ ឬមហានគរ ឬនគរធំ ឬអង្គរ ដែលជាកន្លែងដើមធ្លកបានដុះ។

# III. សេចក្តីបញ្ចប់

ក្រោយពីបានធ្វើការបកស្រាយយ៉ាងក្បោះក្បាយ អំពីដើមកំណើតជាតិខ្មែរដូចខាងលើរួចមក យើងអាចធ្វើសេចក្តីសន្និដ្ឋានបានយ៉ាងប្រត្យក្សជាក់ច្បាស់ឥតមានមន្ទិលសង្ស័យថា ការសិក្សាស្រាវជ្រាវពីដើមកំណើតជាតិខ្មែរពិតជាមានតម្លៃឲ្យយើងបានយល់ដឹងកាន់តែច្បាស់ពីជាតិសាសន៍ និងដើមកំណើតរបស់ខ្លួន។ យើងឃើញថា មានអ្នកសិក្សាស្រាវជ្រាវមួយចំនួន ខិតខំស្វះស្វែងរកវត្ថុតាងជាច្រើន ដើម្បីជាជំនួយក្នុងការដោះស្រាយចំនោទស្តីពីបញ្ហាដើមកំណើតជាតិខ្មែរនេះឯង។ ប៉ុន្តែជាលទ្ធផលយើងសង្កេតឃើញថា មានទស្សនៈផ្សេងៗគ្នាជាច្រើនបានលើកឡើងអំពីបញ្ហានេះដោយសម្អាងលើអំណះអំណាងអ្នកសិក្សាស្រាវជ្រាវនីមួយៗរៀងៗខ្លួន។ ហេតុនេះហើយបានជាចម្ងល់មួយនេះនៅតែស្ថិតនៅក្នុងចិត្តរបស់ប្រជាជនទូទៅ ជាពិសេសអ្នកដែលសិក្សាពីប្រវត្តិសាស្រ្ត និងអរិយធម៌ខ្មែរ។ យ៉ាងណាមិញ ទោះបីជាមានទស្សនៈរបស់អ្នកប្រាជ្ញផ្សេងៗគ្នាជាច្រើនដែលថាខ្មែរ និង ឥណ្ឌាជាជាតិតែមួយ ខ្លះទៀតថាខ្មែរជាជាតិប្រវេសន៍ចេញពីឥណ្ឌាមកលុកលុយដណ្តើមទឹកដីរបស់ជនជាតិអំបូរម៉ាឡេយូ-ប៉ូលីណេស៊ីយែន ឬជនជាតិថៃយ៉ាងណាក៏ដោយក្តី ទស្សនៈដែលមានលក្ខណៈសមហេតុផល និងស្របទៅតាមទស្សនៈរបស់ប្រជាជនខ្មែរភាគច្រើននោះ គឺទស្សនៈដែលថា ខ្មែរជាជាតិពិសេសមួយស្ថិតនៅក្នុងអំបូរខ្មែរ-មនដែលមានវ័យចំណាស់ជាងគេ ហើយបានកកើតនៅលើទឹកដីភូមិភាគអាស៊ីអាគ្នេយ៍នេះតែម្តង។ លើសពីនេះទៅទៀតយើងក៏មានភស្តុតាងបញ្ជាក់យ៉ាងច្បាស់ផងដែរដូចជា សាសនា ទំនៀមទំលាប់ ភាសានិងអក្សរ វត្ថុប្រើប្រាស់ពីបុរាណតាមរយៈស្លានីយ៍បុរេប្រវត្តិ កត្តាជីវសាស្រ្តដូចជាប្រភេទឈាម និងរង្វាស់លលាដ៍ក្បាលជាដើម និង ប្រភពរឿងព្រេងដែលមានតំណាលតៗគ្នាជាយូរលង់ណាស់មកហើយ។

សរុបមក ការសិក្សាពីដើមកំណើតជាតិខ្មែរនេះពិតជាមានសារៈសំខាន់ និងផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ប្រជាពលរដ្ឋខ្មែរនៅក្នុងទូទាំងប្រទេស។ ការយល់ដឹងនេះនឹងបណ្តុះស្មារតីប្រជាពលរដ្ឋខ្មែរ ជាពិសេសកូនខ្មែរជំនាន់ក្រោយដែលជាទំពាំងស្នងឫស្សីឲ្យចេះស្រលាញ់ជាតិរបស់ខ្លួន ពោលគឺមានមោទនភាពក្នុងការកើតមកជាកូនខ្មែរ និងមិនមានការអាក់អន់ចិត្តនឹងជាតិសាសន៍របស់ខ្លួនដោយការភាន់ច្រលំមួយណាឡើយ។ ការបកស្រាយបង្ហាញឡើងនៅក្នុងឯកសារជាច្រើន ធ្វើឲ្យយើងមានទំនុកចិត្តក្នុងការអះអាងថាខ្មែរពិតជាបានកើតនៅ និង មានវប្បធម៌អរិយធម៌ផ្ទាល់ខ្លួនរួចមកហើយ ក្នុងភូមិភាគអាស៊ីអាគ្នេយ៍នេះដូចដែលមានភស្តុតាងបញ្ជាក់

ខាងលើ។ ដូចនេះ ក្នុងនាមយើងជាកុលបុត្រ កុលធីតាខ្មែរជំនាន់ក្រោយគួរគប្បីខិតខំសិក្សា និងស្វែងយល់បន្ថែមទៀតឲ្យកាន់តែច្បាស់ពីដើមកំណើតជាតិខ្លួន ដើម្បីជៀសវាងរាល់ការភាន់ច្រឡំ និងយល់ខុសពីដើមកំណើតនៃជាតិខ្មែរដូចជាទស្សនៈមួយចំនួន កាន់តែច្រើនឡើងទៀត ពោលគឺព្យាយាមស្វះស្វែងរកគំនិតដើម្បីលើកតំកើងជាតិសាសន៍របស់ខ្លួនឲ្យគេទទួលស្គាល់ គោរព និងកោតសរសើរគ្រប់ៗគ្នា ដើម្បីបញ្ជាក់ថាកូនខ្មែរស្គាល់ច្បាស់ពីជាតិសាសន៍ខ្លួនជាងអ្នកណាៗទាំងអស់។ យើងត្រូវរួបរួមគ្នាតស៊ូធ្វើអ្វីៗដើម្បីជាតិសាសន៍របស់យើង ដើម្បីបង្ហាញពីសមត្ថភាព និងភាពប៉ិនប្រសប់របស់យើងដែលជាកូនខ្មែរ៕

# ឯកសារយោង


- សៀវភៅវប្បធម៌ទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ អ៊ុក វិបុល និងលោកសាស្ត្រាចារ្យ នួន សារឿន  ទំព័រទី ៨–១១ និងទំព័រទី៤៧–៦៤
- សៀវភៅប្រវត្តិសាស្ត្ររបស់លោក រស់ ចន្ត្រាបុត្រ ទំព័រទី៣៣-៣៤ បោះពុម្ពនៅឆ្នាំ ១៩៩៨
- សៀវភៅអរិយធម៌ខ្មែរ រៀបរៀងដោយលោក សូ មុយឃៀង លោក ទិត សៀង និងលោក ជា ឈិន ទំព័រទី១៣៧-១៧០
- សៀវភៅអរិយធម៌ខ្មែរ របស់លោកស្រី ត្រឹង ងា បោះពុម្ពនៅគ.ស ១៩៧៥ ព.ស ២៥១៨ ទំព័រទី ១៤-១៥  និងទំព័រទី ៤៧-៥៩
- សៀវភៅប្រវត្តិសាស្ត្រខ្មែរ របស់ លោកស្រី ត្រឹង ងា
- សៀវភៅប្រវត្តិសាស្ត្រកម្ពុជា រៀបរៀងដោយលោកសាស្ត្រាចារ្យ ប្រវត្តិវិទ្យា ដែលមានដូចជា៖ លោក ជូ ច័ន្ទ ដារី  លោក ចាន់ ប៊ុន្នី  លោក ដៀប សុផល  និងលោក ស្រ៊ុន ប៊ុណ្ណារិទ្ធិ ទំព័រទី ១-៣
- សៀវភៅប្រទេសខ្មែរ ពីបុព្វសម័យរហូតដល់ការបោះបង់ចោលរាជធានីអង្គរ ទំព័រទី ២០-៣២ និង ៦៣-៦៨ ។